COSECAM

# របាយការណ៍ស្តីពី

# សិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ ២០០៥

# របស់សម្ព័ន្ធអង្គការ កូសេកាំ

# នៅក្រុងព្រះសីហនុ



**ថ្ងៃទី ៣០-៣១ ខែធ្នូ ឆ្នាំ ២០០៥**

**រៀបចំដោយ**

## សម្ព័ន្ធអង្គការកូសេកាំ

# មាតិកា

**I- សេចក្តីសង្ខេប ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~១**

**II- លទ្ធផលការងារឆ្នាំ ២០០៥ របស់សម្ព័ន្ធអង្គការកូសេកាំ~~~~~~~~~~~~~~~~~~~៣**

១- កម្មវិធីតស៊ូមតិ (Advocacy Program) ---------------------------------- ៣

២- កម្មវិធីស្រាវជ្រាវ (Research) ---------------------------------------- ៤

៣- កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD Program) ------------------ ៤

៤- កម្មវិធីការស្តារនីតិសម្បទា និងសមាហរណកម្ម -------------------------------- ៦

៥- ស្ថានភាពផ្នែកហិរញ្ញវត្ថុ (Financial Situation) ---------------------------- ៨

៦- ការងារផ្នែករដ្ឋបាល និងបោះពុម្ពផ្សាយ (Administration and Publication) ------ ១០

៦.១-ការបោះពុម្ពផ្សាយ ---------------------------------------- ១០

៦.២-ការជ្រើសរើសបុគ្គលិក ------------------------------------- ១០

៦.៣-បុគ្គលិក ហាត់ការ/អ្នកស្ម័គ្រចិត្ត ------------------------------ ១០

**ការសង្ខេប និងពិនិត្យឡើងវិញ នូវគោលនយោបាយ អាណត្តិ និងតួនាទី របស់ សម្ព័ន្ធអង្គការកូសេកាំ**

១- រចនាសម្ព័ន្ធ របស់សម្ព័ន្ធអង្គការកូសេកាំ----------------------------------១១

២- គណៈកម្មការនាយក ---------------------------------------------១១

៣- អង្គការជាសមាជិក ឬក្រុមប្រតិភូ ---------------------------------------១២

៤- លេខាធិការដ្ឋាន ---------------------------------------------១២

៥- អនុគណៈកម្មការ---------------------------------------------១២

**III- ការពិភាក្សាជាក្រុម~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១២**

**IV-ផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០០៦ ~~~~~~~~~~~~~~~~~~~~~~~~~~~~~១៤**

១- កម្មវិធីតស៊ូមតិ --------------------------------------------- ១៤

២-កម្មវិធីស្រាវជ្រាវ ---------------------------------------------- ១៥

៣- កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ---------------------------------១៧
៤- កម្មវិធីស្ថានីតិសម្បទា និងសមាហរណកម្មទៅក្នុងសហគមន៍---------------------- ១៨

**សំណួរពិភាក្សាផ្នែកសមាហរណកម្ម**~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **១៨**

**សំណួរពិភាក្សាផ្នែកអាហារូបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈ** ~~~~~~~~~~~~~~~~~~~~~ **២១**

**សេចក្តីសន្និដ្ឋាន** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **២៣**

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី ១: លទ្ធផលវាយតំលៃសម្ព័ន្ធអង្គការកូសេកាំ ------------------------------២៤

ឧបសម្ព័ន្ធទី ២: ច្បាប់ និង កុមារ នៅប្រទេសកម្ពុជា----------------------------------២៦

ឧបសម្ព័ន្ធទី ៣: បញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលប្រចាំឆ្នាំ ២០០៥-------------- ២៩

ឧបសម្ព័ន្ធទី ៤: កម្មវិធីសិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ ២០០៥ --------------------៣១

# I. សេចក្តីសង្ខេប

សិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០០៥ និងលើកផែនការយុទ្ធសាស្ត្ររបស់សម្ព័ន្ធអង្គការ **កូសេកាំ** ឆ្នាំ២០០៦បានប្រារព្ធឡើងនៅសណ្ឋាគារ ឆ្នេរសមុទ្រ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣០-៣១ ខែធ្នូ ឆ្នាំ ២០០៥ កន្លងទៅក្រោមអធិបតីភាព លោក **សុក សំអឿន** សមាជិកគណៈកម្មការនាយករបស់សម្ព័ន្ធអង្គការកូសេកាំ និងជានាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា លោក **ទួន វិចិត្រ** ប្រធានសម្ព័ន្ធអង្គការ **កូសេកាំ** និងមានការចូលរួមពីសមាជិកសម្ព័ន្ធចំនួន១៦អង្គការ ដែលមានអ្នកចូលរួមសរុបចំនួន ៣០នាក់។

សិក្ខាសាលានេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ដើម្បីបូកសរុបសមិទ្ធផលការងារឆ្នាំ ២០០៥ និងរៀបចំផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំ២០០៦របស់សម្ព័ន្ធអង្គការកូសេកាំ។
- ដើម្បីចែករំលែកបទពិសោធន៍ និងទទួលបានអនុសាសន៍ល្អៗរវាងអង្គការជាសមាជិក នៃសម្ព័ន្ធអង្គការកូសេកាំក្នុងគោលបំណងកែលំអកម្មវិធីទាំងបួនរបស់សម្ព័ន្ធសំរាប់ឆ្នាំ២០០៦។
- ពិភាក្សាស្វែងរកយុទ្ធសាស្ត្រថ្មីៗ ដើម្បីបង្កើនការសហការណ៏រវាងអង្គការជាសមាជិក និងសម្ព័ន្ធអោយកាន់តែប្រសើរឡើង។

ក្នុងរយៈពេលពីរថ្ងៃនៃសិក្ខាសាលានេះ កម្មវិធីនិមួយៗបានបង្ហាញពីសកម្មភាពការងារ និងសមិទ្ធផលដែលទទួលបាន និងបញ្ហាដែលជួបប្រទះក្នុងឆ្នាំកន្លងមកនិងបង្ហាញពីផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំខាងមុខ។ ក្នុងនោះសិក្ខាសាលាបានចែកក្រុមពិភាក្សាស្វែងរកអនុសាសន៍ល្អៗសំរាប់កែលំអគំរោងកម្មវិធីនៅថ្ងៃខាងមុខ។ ក្រៅពីនេះមានការបង្ហាញដោយលោក **ទួន វិចិត្រ** ប្រធានសម្ព័ន្ធអង្គការកូសេកាំពីគោលនយោបាយ អាណត្តិ និង តួនាទីរបស់សម្ព័ន្ធអង្គការកូសេកាំជូនដល់សមាជិកទាំងអស់បានជ្រាបជាពតិមានផងដែរ។

ឆ្លៀតក្នុងឱកាសនោះដែរ លោក **សុក សំអឿន** សមាជិកគណកម្មការនាយក ក៏បានបង្ហាញពី "ច្បាប់ និង កុមារ" ដែលក្នុងនោះលោកបានលើកឡើងពីកង្វះខាតនៃច្បាប់ ជាពិសេសច្បាប់ដែលទាក់ទងនិងវិស័យយុត្តិធមិកុមារនៅកម្ពុជា។

ជាលទ្ធផលសិក្ខាសាលាទទួលបានអនុសាសន៍ល្អៗសំរាប់កែលំអកម្មវិធីនិមួយៗ ក៏ដូចសំរាប់សម្ព័ន្ធអង្គការកូសេកាំ ទាំងមូលក្នុងការអនុវត្តទៅថ្ងៃអនាគត។

**<u>អនុសាសន៍សំខាន់ៗដែលទទួលបានៈ</u>**

- ការប្រជុំអង្គការជាសមាជិក (Delegate) គួររក្សាទុក៣ដងក្នុងមួយឆ្នាំដូចមុនដដែលដោយរាប់បញ្ចូលទាំងការធ្វើសិក្ខាសាលាប្រចាំឆ្នាំនេះផងដែរ ហើយប្រជុំលើកក្រោយគួរអញ្ជើញប្រធានអង្គការជាសមាជិក និង គណៈកម្មការនាយកទាំងអស់មកចូលរួមអោយបានច្រើន។
- ការសំរេចកំណត់ជាផ្លូវការនៃការប្រជុំអង្គការជាសមាជិក (Delegate) គឺរក្សាទុកដដែលនូវការចូលរួមប្រជុំរាល់៤ខែម្តង គឺលើកទី១ នៅខែមេសា លើកទី២ នៅខែសីហា និងលើកទី៣ នៅខែធ្នូ ឆ្នាំ ២០០៦ ចំណែកកាលបរិច្ឆេទនឹងកំណត់នៅពេលក្រោយ។
- សម្ព័ន្ធអង្គការកូសេកាំត្រូវធ្វើការសហការណ៍ជាមួយអង្គការដែលមានសក្តានុពល ដើម្បីធ្វើការទាក់ទាញការចូលរួមអោយបានទៀងទាត់។
- របៀបវារៈសូមឱ្យគ្របដណ្តប់ ឬទាក់ទងនឹងផលប្រយោជន៍របស់អង្គកាសមាជិកររបស់សម្ព័ន្ធ។
- អង្គការជាសមាជិកត្រូវចាត់តាំងបុគ្គលិកណាម្នាក់ ដែលមានជំនាញពាក់ព័ន្ធចូលរួមក្នុងការងារតស៊ូមតិ។
- ក្រុមសំរបសំរួលគួរផ្តល់ឱ្យអនុគណៈកម្មការ (Sub-Committee) នូវការទទួលខុសត្រូវទៅលើផែនការសកម្មភាពនៃក្រុមកុមារតស៊ូ (Girl Speak-out).
- សូមផ្តល់ពត៌មានពីការចូលរួមរបស់កុមារ និងរបៀបវារៈមុននឹងអញ្ជើញកុមារទៅចូលរួមប្រជុំ និង ផ្តល់លទ្ធផលនៃការចូលរួមរបស់កុមារដល់សាម៉ីអង្គការ។
- បង្កើតឯកសាររួមគ្នាជាមួយសមាជិក ដើម្បីជាការលើកទឹកចិត្តដូចជាការបញ្ចូលសកម្មភាពរបស់អង្គការជាសមាជិក។
- ដើរតួនាទីជាអ្នកសំរបសំរួលប្រកបដោយប្រសិទ្ធិភាព។
- អង្គការពាក់ព័ន្ធគួរសហការគ្នាដើម្បីឱ្យអតិថិជនងាយទទួលបានសេវាកម្ម។
- សម្ព័ន្ធអង្គការកូសេកាំគួរតែធ្វើតាមភ្នាក់ងារដទៃទៀតដូចជាៈអង្គការ IOM, ក្រសួងសង្គមកិច្ច និងអង្គការ UNICEF ដើម្បីធានាឱ្យមាននិរន្តរភាព និងមានភាពសហការណ៍គ្នា។
- សម្ព័ន្ធអង្គការកូសេកាំគួរតែធ្វើការសហការណ៍ជាមួយក្រសួងសង្គមកិច្ច ដើម្បីតាមដានករណីនិមួយៗ។
- សូមអោយសមាជិកនៅក្នុងតំបន់ណា ដែលបានបញ្ជូនអតិថិជនធ្វើការតាមដាន និងបិទករណីរបស់អតិថិជន។

## II- លទ្ធផលការងារឆ្នាំ ២០០៥ របស់សម្ព័ន្ធអង្គការកូសេកាំ

### ១- កម្មវិធីតស៊ូមតិ (Advocacy Program)

**គោលបំណង:**

គោលបំណងសំខាន់របស់គំរោងតស៊ូមតិ គឺ ប្រមូលពតិមាន ទិន្នន័យ ដោយផ្តោតខ្លាំង ពីគុណភាព ដើម្បីធ្វើការតស៊ូមតិ ទប់ស្កាត់ និងរកយុត្តិធមិ ឱ្យជនរងគ្រោះដោយការកេងប្រវ័ញ្ច ផ្លូវភេទ និងការរំលោភសេពសន្ថវៈទៅលើកុមារនៅក្នុងប្រទេសកម្ពុជា ហើយធ្វើអន្តរាគមន៍ទៅស្ថាប័នដែលពាក់ពន្ធ័ដើម្បីរកដំណោះស្រាយដែលសមស្រប និងប្រកបដោយប្រសិទ្ធិភាពតាមរយៈកិច្ចពិភាក្សាតុមូលជាមួយរដ្ឋាភិបាល និងភ្នាក់ងារគាំទ្រជនរងគ្រោះពាក់ព័ន្ធដទៃទៀត។

**លទ្ធផលទទួលបាន:**

- បានរៀបចំពង្រាងអនុសារណៈនៃការយោគយល់ស្តីពីសិទ្ធិជាអាណាព្យាបាលជាភាសាខ្មែរ និង ភាសាអង់គ្លេស។
- រៀបចំសិក្ខាសាលាស្តីពីពង្រាងអនុសារណៈនៃការយោគយល់សិទ្ធិជាអាណាព្យាបាល ដែលមានអ្នកចូលរួមចំនួន ៣៥ នាក់មកពីអង្គការ និងស្ថាប័នពាក់ព័ន្ធនានាចំនួន៣០។
- បានពង្រាងឯកសារសង្ខេបស្តីពី ការកាត់បន្ថយការរំលោភសេពសន្ថវៈលើកុមារ និងកែលំអឯកសារនេះ។
- បានរៀបចំក្រុមកុមារដែលមានសមាជិកចំនួន២០នាក់ ដែលមកពីមណ្ឌលស្នាក់នៅរបស់អង្គការនានានៅភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន។ ក្រុមកុមារបានដាក់ឈ្មោះក្រុមនេះថា "ក្រុមកុមារតស៊ូ" ដោយកំណត់ជួបគ្នារៀងរាល់ ៦សប្តាហ៍ម្តង។
- បញ្ចប់របាយការណ៏អំពី "របាយការណ៏សរុបលទ្ធផលការធ្វើទស្សនកិច្ចមណ្ឌលដែលមានជាភាសាខ្មែរ និងភាសាអង់គ្លេស" ។
- បានចែករំលែកពតិមានស្តីពីបញ្ហាការតស៊ូមតិតាមរយៈការប្រជុំអនុគណៈកម្មការតស៊ូមតិចំនួន២ដង ក្នុងឆ្នាំ ២០០៥។
- បានចូលរួមរៀបចំទិវាសិទ្ធិមនុស្សអន្តរជាតិថ្ងៃ ១០ធ្នូ ដែលមានអង្គការជាង ៦០ និងអ្នកចូលរួមចំនួន ២០ ០០០ នាក់នៅទូទាំងប្រទេស ដែលបានប្រារព្ធធ្វើឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក។

**បញ្ហាជួបប្រទះ:**

- ពន្យាពេលប្រជុំជាច្រើនដងដោយសារសមាជិកក្រុមការងារជាប់រវល់។

- កង្វះមូលនិធិសំរាប់គាំទ្រកម្មវិធីតស៊ូមតិ ។
- ការចូលរួមរបស់សមាជិកក្រុមការងារនៅមានកំរិត ។

## ២. កម្មវិធីស្រាវជ្រាវ (Research)

ដោយឡែកសំរាប់កម្មវិធីស្រាវជ្រាវដែលកូសេកាំបានធ្វើក្នុងឆ្នាំ២០០៥កន្លងមករួមមានៈ

**លទ្ធផលទទួលបានៈ**

- បានសហការជាមួយអង្គការ AIDeTous គឺបណ្ឌិត ថូម៉ាស់ ហ្វេឌ៊ីរិច ក្នុងការស្រាវជ្រាវពីផលប៉ះពាល់ នៃការបិទតំបន់ស្វាយប៉ាកនៅទីក្រុងភ្នំពេញ ។
- បានបញ្ចប់របាយការណ៍ស្តីពី ការសិក្សាវាយតំលៃពីស្ថានភាពនៃអ្នកចូលចិត្តរួមភេទជាមួយកុមារ នៅក្រុងព្រះសីហនុ (ជាភាសាអង់គ្លេស) ។
- បានបញ្ចប់របាយការណ៍ស្តីពី ការសិក្សាពីរូបភាពផ្សេងៗនៃពេស្យាចារក្រោយពីបិទតំបន់ស្វាយប៉ាក ។
- លទ្ធផលនៃការស្រាវជ្រាវទាំងនេះត្រូវបានប្រើប្រាស់ជាឯកសារយោងសំរាប់ស្ថាប័នអនុវត្តការងារ ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងកិច្ចអន្តរាគមន៍នូវបញ្ហាដែលពាក់ព័ន្ធ ។

**បញ្ហាជួបប្រទះ**

- ខ្វះថវិកាសំរាប់សិក្សាពីការតាមដានអំពីផលប៉ះពាល់នៃការបិទតំបន់ស្វាយប៉ាក

## ៣. កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD Program)

ចំពោះកម្មវិធីនេះ សម្ព័ន្ធអង្គការកូសេកាំបានធ្វើសកម្មភាពលើគំរោងធំៗចំនួន៣គឺៈ គំរោងផ្តល់ការបណ្តុះបណ្តាល, គំរោងដោះស្រាយបញ្ហាចំរុះរបស់កុមាររងគ្រោះ និង គំរោងវេទិកាមណ្ឌលថែទាំកុមារ ដែលទទួលបានលទ្ធផលដូចខាងក្រោមៈ

**លទ្ធផលទទួលបានៈ**

- ផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធសាស្ត្រនៃការគ្រប់គ្រងមណ្ឌលដល់សិក្ខាកាមចំនួន ២០នាក់ មកពីអង្គការ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនានា ។
- បានរៀបចំប្រជុំរវាងសិក្ខាកាមវគ្គប្រឹក្សាចិត្តសាស្ត្រសង្គម ដែលបានបញ្ចប់វគ្គមូលដ្ឋានកាលពីឆ្នាំ ២០០៤ ជាមួយអ្នកបណ្តុះបណ្តាលមកពីសហរដ្ឋអាមេរិកដើម្បីស្វែងយល់ពីបញ្ហាដែលសិក្ខាកាមជួបប្រទះ និង តំរូវការបណ្តុះបណ្តាលសំរាប់វគ្គក្រោយ ។

- បានប្រជុំ៤លើករវាងគ្រូជំនាញផ្នែកចិត្តសាស្ត្រសង្គមជាមួយសិក្ខាកាមចាស់ ដើម្បីចែករំលែកបទពិសោធន៍ ចំណេះដឹងពីគ្នាទៅវិញទៅមក និងជួយរកដំណោះស្រាយសមស្របសំរាប់ការងារប្រចាំថ្ងៃ ។
- បានធ្វើការប៉ាន់ប្រមាណតំរូវការវគ្គបណ្តុះបណ្តាលសំរាប់ឆ្នាំ ២០០៦ ជាមួយអង្គការជាសមាជិកចំនួន២២ អង្គការ,ដែលមានបុគ្គលិកចំនួន ៣០៩ នាក់ ។
- បានបញ្ចប់របាយការណ៍លទ្ធផលនៃការប៉ាន់ប្រមាណតំរូវការវគ្គបណ្តុះបណ្តាល
- បានរៀបចំប្រជុំដើម្បីបង្ហាញលទ្ធផលនៃការប៉ាន់ប្រមាណតំរូវការវគ្គបណ្តុះបណ្តាល និងបង្ហាញពីលក្ខណៈសម្បត្តិរបស់សិក្ខាកាមសំរាប់វគ្គបណ្តុះបណ្តាលនេះដែលមានអ្នកចូលរួមសរុបចំនួន៥០នាក់មកពីអង្គការជាសមាជិក២២ ។
- បានបង្កើតគណៈកម្មការសំរាប់ការបណ្តុះបណ្តាលដែលមានសមាជិកចំនួន ៤រូបគឺៈ ប្រធានសម្ព័ន្ធ, ទីប្រឹក្សា, អ្នកសំរបសំរួលវគ្គបណ្តុះបណ្តាល និងមន្ត្រីកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ។
- បានជ្រើសរើសអ្នកសំរបសំរួលម្នាក់ និងអ្នកបណ្តុះបណ្តាលដែលមានសមត្ថភាពចំនួន៣នាក់សំរាប់វគ្គគ្រប់គ្រងអង្គការនិងគ្រប់គ្រងកម្មវិធី ។
- បានទទួលពាក្យសុំចូលរៀនវគ្គបណ្តុះបណ្តាលពីបេក្ខជន ១៣៤ នាក់ មកពី៣២អង្គការ និងស្ថាប័នរដ្ឋចំនួន ២ស្ថាប័ន។ បេក្ខជនទាំងអស់បានសុំរៀនកម្មវិធីគ្រប់គ្រងអង្គការ និងកម្មវិធីចំនួន ៣៦ នាក់, អនុវត្តកម្មវិធីចំនួន ៥៩ នាក់ និង ការប្រឹក្សាយោបល់ចំនួន ៣៩ នាក់ ។
- បានរៀបចំការប្រជុំក្រុមកុមារចំនួន ៥លើក ដែលមានកុមារចូលរួមជាមធ្យមចំនួន ១៨ នាក់។ ក្រុមកុមារនេះបានដាក់ឈ្មោះក្រុមដោយខ្លួនឯងថា "**ក្រុមកុមារតស៊ូ**" ។
- បានរៀបចំប្រជុំក្រុមការងារមណ្ឌលចំនួន៦លើក ដែលមានអ្នកចូលរួមជាមធ្យមចំនួន ១២ នាក់។ សមាជិកអង្គប្រជុំបានចែករំលែកបទពិសោធន៍ស្តីពីការងារមណ្ឌលពីគ្នាទៅវិញទៅមក និងជួយធ្វើផែនការសំរាប់ក្រុមកុមារផងដែរ ។
- បានចូលរួមប្រជុំ៨លើក ក្នុងការពង្រាងបទដ្ឋានអប្បរមាស្តីពីការថែទាំកុមារតាមសហគមន៍, ការថែទាំកុមារតាមផ្ទះ និង ការថែទាំកុមារតាមវត្តអារាម ។

**បញ្ហាជួបប្រទះ**

- សមត្ថភាពអ្នកសំរបសំរួលមួយចំនួនក្នុងវគ្គគ្រប់គ្រងមណ្ឌលនៅមានកំរិត
- មានការលំបាកក្នុងការជ្រើសរើសគ្រូបណ្តុះបណ្តាលដែលមានសមត្ថភាពសំរាប់វគ្គប្រឹក្សាយោបល់ចិត្តសាស្ត្រសង្គម ។

- សមាជិកចូលរួមប្រជុំក្រុមការងារមណ្ឌលនៅមានកំរិតព្រោះសមាជិកភាគច្រើនជាប់រវល់ការងារស្នូល ។
- ការចូលរួមរបស់កុមារក្នុងក្រុមកុមារតស៊ូនៅមានកំរិត ដោយអង្គការមួយចំនួនមិនអនុញ្ញាតិឱ្យកុមារចេញពីមណ្ឌល ។

## ៤- កម្មវិធីការស្តារនីតិសម្បទា និងសមាហរណកម្ម

**Rehabilitation & Reintegration Program**

**គោលបំណង:**

បើកទូលាយនូវជំរើសផ្សេងៗនៃជីវិតដល់កុមារ និងស្ត្រីដែលទើបរួចផុតពីគ្រោះថ្នាក់ដោយការកេងប្រវ័ញ្ចផ្លូវភេទ និង ពលកម្ម ដើម្បីឱ្យពួកគេមានលទ្ធភាពរកចំណូលផ្គត់ផ្គង់ខ្លួនឯងបានគ្រប់គ្រាន់ និងជួយកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ពួកគេពីការធ្វើអាជីវកម្មរបស់អ្នកដទៃ ។

**លទ្ធផលទទួលបាន:**

- បានប្រជុំអនុគណៈកម្មការកម្មវិធីម្តងដោយប្រជុំរួមគ្នាជាអនុគណៈកម្មការនៃកម្មវិធី៣ផ្សេងទៀត
- បានដំណើរប្រជុំបណ្តាញការងារកម្មវិធី VTF នៅតំបន់សៀមរាបចំនួន១០ដង, នៅតំបន់បាត់ដំបងចំនួន១០ដង និងនៅភ្នំពេញចំនួន០១ ដង ។
- បានធ្វើសំភាសន៍អតិថិជនចំនួន២១២នាក់ដើម្បីផ្តល់អាហារូបករណ៍ ហើយក្នុងនោះអតិថិជនចំនួន៨១នាក់បានបញ្ជូនអោយចូលរៀនជំនាញ ។ ក្រោយពេលរៀនចប់ពួកគេទទួលបានការងារធ្វើជាបន្តបន្ទាប់ ។ ចំពោះអតិថិជនដែលនៅសល់បានត្រៀមដាក់ឱ្យចូលរៀននៅឆ្នាំ ២០០៦ (ខែតុលា ២០០៥-កញ្ញា ២០០៦) ។
- ក្រៅពីសមាជិកសម្ព័ន្ធអង្គការកូសេកាំចំនួន២៣ កម្មវិធីស្តារនិតិសម្បទា និងសមាហរណកម្មក៏បានសហការជាមួយអង្គការដៃគូប្រមាណជាង ៤០ អង្គការនៅទូទាំងប្រទេសក្នុងគោលបំណងដើម្បីគាំទ្រឱ្យដំណើរការគំរោងVTFទទួលបានជោគជ័យ ។
- សកម្មភាពស្រាវជ្រាវទីផ្សារបាននឹងកំពុងបន្តនៅក្នុងតំបន់សំខាន់ៗទាំង៣គឺ ភ្នំពេញ សៀមរាប និង បាត់ដំបង ។
- ស្ថាប័នឯកជន/អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នបណ្តុះបណ្តាលជំនាញចំនួន១០៨បានកំណត់និងជួបជាមួយ ។ ក្នុងនោះមាន៣២ស្ថាប័នដែលមានសក្តានុពល និងអាចទទួលអតិថិជនចូលរៀន

ជំនាញបានដូចជាៈ ជំនាញកែសម្ផស្ស សំអាងការ កាត់ដេរ/ដេរម៉ូត ចំលាក់ថ្ម ត្បាញល្គាក់ ធ្វើនំនិងម្ហូប កាត់សក់ ផ្នែកជួសជុលគ្រឿងអេឡិចត្រូនិច និងផ្នែកសណ្ឋាគារ ។ល។

- ដំណើការប្រឹក្សាយោបល់ពីការងារ និងការណែនាំបានប្រព្រឹត្តិទៅចំពោះគ្រប់អតិថិជនគោលដៅទាំងអស់ដែលកំពុងរៀនជំនាញវិជ្ជាជីវៈនៅក្នុងតំបន់ទាំងបី ភ្នំពេញ បាត់ដំបង និង សៀមរាប។ ការប្រឹក្សាយោបល់បានធ្វើឡើងដោយភ្នាក់ងារប្រចាំតំបន់នីមួយៗ និងមានកិច្ចសហការណ៍ពីស្ថាប័នបណ្តុះបណ្តាល ជាលក្ខណៈបុគ្គល ឬជាក្រុម ហើយប្រធានបទបានផ្តោតទៅលើៈ ពង្រឹងអត្តចរិក និងអាកប្បកិរិយា របស់អតិថិជន និងលើកទឹកចិត្តពួកគេក្នុងកំឡុងពេលបណ្តុះបណ្តាល និង បំពេញការងារ ដូចជាបំណិន ជីវិត សុខភាព និង អក្ខរកម្ម ។ល។
- ផ្តល់ការណែនាំដល់អតិថិជនពីទិសដៅអនាគតថាតើគួរធ្វើដូចម្តេចដើម្បីទទួលបានប្រាក់ចំណូលតាមរយៈការប្រើប្រាស់ជំនាញដែលបានរៀនទាំងនេះរួមបញ្ចូលនូវវិធីសាស្ត្រក្នុងការទំនាក់ទំនងសង្គម និងឆ្លើយតបទៅនឹងតំរូវការទីផ្សារការងារ។
- បានផ្តល់អាហារូបករណ៍ដល់អតិថិជនបានរៀនចប់ជំនាញវិជ្ជាជីវៈសំរាប់ឆ្នាំ២០០៤ចំនួន៦០នាក់។ ក្នុងនោះអតិថិចនចំនួន៥១នាក់មានការងារធ្វើ និងទទួលបានកំរៃពី ៣០-៧០ដុល្លារ ក្នុងមួយខែ។
- បានផ្តល់អាហារូបករណ៍ដល់អតិថិជនសំរាប់ឆ្នាំ២០០៥បានចំនួន៨១នាក់ ដែលក្នុងនោះអតិថិជនចំនួន៥៦នាក់បានរៀនចប់ ហើយអតិថិជនចំនួន៥១នាក់មានការងារធ្វើនិងទទួលបានកំរៃពី ៣០-៤០ ដុល្លារក្នុង មួយខែរួមនឹង អត្ថប្រយោជន៏ដទៃទៀតដូចជា ការស្នាក់នៅ និងការហូបចុក។
- អាហារូបករណ៍សំរាប់ឆ្នាំ២០០៦មានគំរោងផ្តល់អោយអតិថិជនចំនួន៩០នាក់។ មកដល់ចុង ខែធ្នូ ២០០៥ បានផ្តល់អាហារូបករណ៍ដល់អតិថិជនចំនួន៣១នាក់ អោយចូលរៀនជំនាញនានា ដែលក្នុងនោះអតិថិជនចំនួន១២នាក់នាក់បានរៀនចប់និងមានការងារធ្វើដោយទទួលប្រាក់កំរៃ៤០ដុល្លារក្នុងមួយខែ។

**បញ្ហាជួបប្រទះ**

- មានការពន្យាពេលប្រជុំអនុគណៈកម្មការ និងប្រជុំបណ្តាញការងារ VTF ជាច្រើនលើកដោយសារអ្នកចូលរួមមានចំនួនតិចពេក។
- អ្នកចូលរួមប្រជុំបណ្តាញការងារ VTF នៅតំបន់ភ្នំពេញមានចំនួនតិចតួច។
- ការកំណត់កាលបរិច្ឆេទប្រជុំការងារបណ្តាញរបស់សមាជិកនៅតំបន់សៀមរាប និងបាត់ដំបងមិនស៊ីសង្វាក់គ្នាជាហេតុនាំអោយមានការផ្លាស់ប្តូរពេលជាញឹកញាប់ និងផ្លាស់ប្តូរតំណាងជាញឹកញាប់ដែរ។

- អតិថិជនដែលបញ្ជូនមកពីមណ្ឌលភាគច្រើនបានបោះបង់ចោលការរៀនជំនាញ ។
- អតិថិជនមានការផ្លាស់ប្តូរចិត្តជាច្រើនដងទៅលើកន្លែងធ្វើការងារ ។
- អង្គការដែលដាក់ពាក្យតំណាងអោយអតិថិជន តែងតែគិតពីគោលការណ៍ផ្ទាល់របស់អង្គការជាជាងគោលការណ៍របស់គំរោង VTF ។
- មិនសូវមានការសហការណ៍ពីអង្គការមួយចំនួនដែលបញ្ជូនអតិថិជនមកទទួលអាហារូបករណ៍ពីគំរោង VTF ។

## ៥- ស្ថានភាពផ្នែកហិរញ្ញវត្ថុ (Financial Situation)

**គោលបំណង:**

បង្ហាញពីសមិទ្ធិផល និងជោគជ័យនៃដំណើរប្រតិបត្តិការសកម្មភាពគ្រប់គំរោងរបស់សម្ព័ន្ធអង្គការកូសេកាំ ក្រោមជំនួយថវិការបស់ម្ចាស់ជំនួយដែលបង្ហាញជូនដូចខាងក្រោម:

**លទ្ធផលទទួលបាន:**

សម្ព័ន្ធអង្គការកូសេកាំទទួលបានមូលនិធិសរុបចំនួន **២៩៨.៦៣៣.៨២**ដុល្លារអាមេរិក ដែលក្នុងនោះទទួលបានពី:

- អង្គការមូលនិធិអាស៊ី ចំនួន ៦៤%
- មូលនិធិ SKN ចំនួន ១៥%
- មូលនិធិ KIA ចំនួន ១៥%
- អង្គការ AJWSចំនួន ៣%
- ២% ទៀតជាមូលនិធិក្នុងឆ្នាំ ២០០៤ ដែលទទួលបានមកពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា និង អង្គការ អុកស្វាម ជីប៊ី (CIDA & OxfamGB) ហើយមូលនិធិនេះយើងបានអនុវត្តនៅឆ្នាំ ២០០៥ នេះ ។
- ១%ទៀត គឺជាប្រាក់សន្សំរបស់សម្ព័ន្ធអង្គការកូសេកាំដែលបានពីអត្រាការប្រាក់ធនាគារ និងប្រាក់ចំណូលផ្សេងៗទៀត ។

## តារាងទី១: ម្ចាស់ជំនួយរបស់សម្ព័ន្ធអង្គការកូសេកាំ

| Nº | Donors | USD |
|---|---|---|
| 1 | SKN | 44,902.84 |
| 2 | KIA | 45,081.38 |
| 3 | TAF | 191,075.47 |
| 4 | AJWS | 7,500.00 |
| 5 | COSECAM | 2,934.73 |
| 6 | Funds 2004 | 7,139.00 |
| **Total** | | **298,633.42** |




## តារាងទី២: គំរោងថវិកា និងការចំណាយជាក់ស្តែងរបស់សម្ព័ន្ធអង្គការកូសេកាំ

| លេខរៀង | បរិយាយ | ថវិកា ដុល្លារអាមេរិក | ចំណាយ ដុល្លារអាមេរិក |
|---|---|---|---|
| ១ | បុគ្គលិកក្នុងស្រុក | ៧៨.១៨១,០០ | ៦០.៥២៩.៥២ |
| ២ | បុគ្គលិកបរទេស | ៤៤.៣០០,០០ | ៣៩.០១០,៩០ |
| ៣ | ការិយាល័យ | ៣២.២៤០,០០ | ២៣.៦៦១,៧០ |
| ៤ | កម្មវិធីតស៊ូមតិ | ២.៣០០,០០ | ១.៤៩៦,២៩ |
| ៥ | កម្មវិធីស្រាវជ្រាវ | ៥.០០០,០០ | ៣.៩០៦,១៩ |
| ៦ | កម្មវិធីអភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្ស | ១៨.៣០៥,០០ | ១១.២០៥,៥១ |
| ៧ | កម្មវិធីស្តានីតិសម្បទានិងសមាហរណ៍កម្ម | ១៤៩.៥២៩,០០ | ១១៥.៣៩២,២៣ |
| សរុប | | ៣២៩.៨៥៥,០០ | ២៩៥.២០២,៣៤ |
| | | | |

តាមតារាងទី២ បង្ហាញថា កម្មវិធីសមាហរណកម្មនិងស្តារនិតិសម្បទាមានការចំណាយខ្ពស់ជាងគេ។ កម្មវិធីនេះបានទទួលជំនួយពីមូលនិធិអាស៊ី បន្ទាប់មកគឺកម្មវិធីអភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្ស។ ចំនែកកម្មវិធីដែលមានការចំណាយទាបជាងគេគឺកម្មវិធីតស៊ូមតិព្រោះពុំសូវមានម្ចាស់ជំនួយឧបត្ថម្ភប៉ុន្តែនៅឆ្នាំក្រោយ កម្មវិធីនេះបានទទួលមូលនិធិពីស្ថានទូតអង់គ្លេស។

**តារាងទី៣: ថវិកាទទួលបាន និង ចំណាយជាក់ស្តែង**

| Type | Date | USD | % |
|---|---|---|---|
| Total Budget | from Jan-Nov.05 | 298,633.42 | 100.00% |
| Total expense | from Jan-Nov.05 | 255,202.32 | 85.46% |
| **Total funds remain** | | **$ 43,431.10** | **14.54%** |




សំរាប់ឆ្នាំ២០០៥ នេះក្នុងដំណើរប្រតិបត្តិការកម្មវិធី ពុំមានគំរោងណាមួយចំណាយលើសខ្ទង់ឡើយ ។

## ៦- ការងារផ្នែករដ្ឋបាល និងបោះពុម្ពផ្សាយ (Administration and Publication)

**សកម្មភាព:**

### *៦.១-ការបោះពុម្ពផ្សាយ*

- Cambodian Commodity Chain Analysis Study, Volume 1: Comparative Industry Assessments, February 2005, Emerging Markets Consultants (English)
- Cambodian Commodity Chain Analysis Study, Volume 2: Job Facilitation Program Recommendations, February 2005, Emerging Markets Consultants (English)
- Overview Activity Program 2005, May 2005 (English and Khmer)
- Training Needs Assessment for NGO staff, May 2005, Khun Sithon

### *៦.២-ការជ្រើសរើសបុគ្គលិក*

- លោក ឯម ពូល មន្ត្រីកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ចាប់ផ្តើមធ្វើការនៅខែសីហា ឆ្នាំ២០០៥ ។
- លោក ឆន វុទ្ធី មន្ត្រីទំនាក់ទំនងសាធារណៈចាប់ផ្តើមធ្វើការនៅខែធ្នូ ឆ្នាំ២០០៥ ។.
- កំពុងដំណើរការជ្រើសរើសមន្ត្រីកម្មវិធីផ្នែកតស៊ូមតិ ។

### *៦.៣-បុគ្គលិក ហាត់ការ/អ្នកស្ម័គ្រចិត្ត*

- លោក សុក សុធន ជំនួយការផ្នែករដ្ឋបាល និងហិរញ្ញវត្ថុចាប់ផ្តើមធ្វើការតាំងពីខែកុម្ភៈ ឆ្នាំ ២០០៤
- កញ្ញា Diane Lawrence មន្ត្រីគ្រប់គ្រងការិយាល័យ
- កញ្ញា CAROLINE ជួយផ្នែកកម្មវិធីតស៊ូមតិ
- កញ្ញា JUDITH ជួយផ្នែកកម្មស្រាវជ្រាវ
- កញ្ញា Gal Isabel ជួយផ្នែកកម្មវិធីពតិមានវិទ្យា តែបានចប់ហើយ ។

# ការសង្ខេប និងពិនិត្យឡើងវិញ នូវគោលនយោបាយ អាណត្តិ និងតួនាទី របស់សម្ព័ន្ធអង្គការកូសេកាំ

## ១- រចនាសម្ព័ន្ធរបស់សម្ព័ន្ធអង្គការកូសេកាំ

លោក ទូន វិចិត្រ ប្រធានសម្ព័ន្ធអង្គការកូសេកាំបានរំលឹកដោយសង្ខេបអំពីរចនាសម្ព័ន្ធរបស់សម្ព័ន្ធអង្គការកូសេកាំ ដែលមានសមាសភាព ៤ផ្នែកសំខាន់ៗ គឺ គណៈកម្មការនាយក, ក្រុមប្រតិភូដែលជាអង្គការសមាជិក, លេខាធិការដ្ឋាន និងអនុគណៈកម្មការ។ កូសេកាំត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ដែលផ្តួចផ្តើមឡើងដោយអង្គការធំៗចំនួនបីរួមមានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) សមាគមអាដហុក (ADHOC) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ហើយជាបន្តបន្ទាប់មានអង្គការសមាជិកចូលរួមមានចំនួនកើនឡើង ៥,៧,១៥,១៨ និងបច្ចុប្បន្នមានចំនួន២៣អង្គការ។ អង្គការដែលជាសមាជិករបស់សម្ព័ន្ធអង្គការកូសេកាំមាន៤ប្រភេទធំៗគឺ អង្គការផ្នែកសិទ្ធិមនុស្ស អង្គការជំនួយផ្នែកច្បាប់ អង្គការ ដែលមានមណ្ឌលជួយជនរងគ្រោះ និង ងាយរងគ្រោះដោយការជួញដូរ អំពើហិង្សា ការរកេងប្រវ័ញ្ច និងរំលោភ សេពសន្ថវៈ និងអង្គការ ដែលធ្វើការងារក្នុងគោលបំណងអភិវឌ្ឍន៍កុមារ និងគ្រួសាររបស់ពួកគេនៅក្នុងសហគមន៍ ។

រចនាសម្ព័ន្ធរបស់សម្ព័ន្ធអង្គការកូសេកាំដែលក្នុងនោះមានឋានានុក្រមធំៗចំនួន៣ គឺ គណៈកម្មការនាយក, ក្រុមប្រតិភូ និងអនុគណៈកម្មការ ហើយដែលផ្នែកនិមួយៗមានតួនាទីនិងការទទួលត្រូវខុសៗគ្នា។ គណៈកម្មការនាយកមានចំនួន ៥រូប ដែលបានបោះឆ្នោតជ្រើសរើសដោយអង្គការជាសមាជិកទាំងអស់ក្នុងនោះមានសមាសភាពៈ ទី១ លោក សុក សំអឿន, ទី២ លោក ធន សារ៉ាយ, ទី៣ លោកស្រី អ៊ុង ចាន់ថុល, ទី៤ លោក នុយ បូរ៉ា និងទី៥ លោកស្រី ឃូ អក្ខរា ប៉ុន្តែបច្ចុប្បន្ន លោកស្រី ឃូ អក្ខរា បានលាឈប់ហើយៗយើងមិនទាន់ជ្រើសរើសសមាសភាពថ្មីជំនួសនៅឡើយទេ តែទោះជាយ៉ាងណាយើងនឹងជ្រើសរើសនៅពេលឆាប់ៗនេះ។

## ២. គណៈកម្មការនាយក

គណៈកម្មការនាយកគឺ ជាអ្នកគ្រប់គ្រងទៅលើសម្ព័ន្ធទាំងមូល។ គណៈកម្មការនេះត្រូវបានដូរឈ្មោះនៅចុងឆ្នាំ ២០០៣ ដើម្បីតំរូវទៅតាមចរិកលក្ខណៈការងាររបស់សម្ព័ន្ធ។ គណៈកម្មការនេះត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតក្នុងចំណោមអង្គការតំណាងដែលមានបេក្ខជនជា (នាយក/ប្រធាន) ប្រកបដោយសក្តានុពល ដែលមានភាពល្បីឈ្មោះ សកម្មមានវ៉ោហា មានពេលវេលាសមស្រប និងបទពិសោធន៍គ្រប់គ្រាន់ដែលអាចផ្តល់ជាគំនិតទៅលើយុទ្ធសាស្ត្រកម្មវិធី ទិសដៅសម្ព័ន្ធ អនុម័តគោលនយោបាយ និងថវិកាប្រចាំឆ្នាំ តែងតាំងប្រធានសម្ព័ន្ធ និងជាតំណាងក្នុងការទំនាក់ទំនងខាងក្រៅរបស់សម្ព័ន្ធ ជួយរកថវិកា និងពិនិត្យរាល់សមិទ្ធផលរបស់សម្ព័ន្ធ។

## ៣. អង្គការជាសមាជិក ឬក្រុមប្រតិភូ

បច្ចុប្បន្ននេះសម្ព័ន្ធមានអង្គការជាសមាជិក ឬក្រុមប្រតិភូមានសរុបចំនួន២៣ ដែលចូលរួមប្រជុំជាមួយសម្ព័ន្ធចំនួនបីដងក្នុងមួយឆ្នាំ ដើម្បីទទួលពតិមានពីលទ្ធផលការងាររបស់សម្ព័ន្ធ និងផ្តល់មតិលើការផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំបន្ទាប់។

## ៤. លេខាធិការដ្ឋាន

លេខាធិការដ្ឋានជាកន្លែងដែលគ្រប់គ្រងដោយប្រធានសម្ព័ន្ធ ក្នុងនោះមានការផ្តល់ប្រឹក្សាយោបល់ណែនាំពីទីប្រឹក្សាបច្ចេកទេស និងគណៈកម្មការនាយក។ ហើយលេខាធិការដ្ឋានជាអ្នកទទួលខុសត្រូវក្នុងការសំរបសំរួល និងគាំទ្រអង្គការជាសមាជិកក្នុងការអនុវត្តគំរោងកម្មវិធី ផ្តល់នូវបច្ចេកទេស កសាងសមត្ថភាព និងគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ។

## ៥. អនុគណៈកម្មការ

សម្ព័ន្ធអង្គការកូសេកាំមានអនុគណៈកម្មការបួន គឺមានអនុគណៈកម្មការកម្មវិធិតស៊ូមតិ, អនុគណៈកម្មការកម្មវិធីស្រាវជ្រាវ, អនុគណៈកម្មការកម្មវិធិអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស, និងអនុគណៈកម្មការស្តារនិតិសម្បទា និងសមាហរណកម្ម។ ប៉ុន្តែតាមរយៈសិក្ខាសាលាបូកសរុបលទ្ធផលនៅចុងឆ្នាំ ២០០៤ ក្នុងខែធ្នូ អង្គការជាសមាជិកបានឯកភាពទុកតែ ៣ អនុគណៈកម្មាការ ដោយបញ្ចូលអនុគណៈកម្មាការស្រាវជ្រាវជាមួយអនុគណៈកម្មាការតស៊ូមតិ ចំណែកអនុគណៈកម្មាពីរទៀតគឺនៅដដែល។

## III- ការពិភាក្សាជាក្រុម

**១- តើគណៈកម្មការនាយកគួរមានតួនាទីអ្វីខ្លះបន្ថែម ដើម្បីឱ្យការងាររបស់សម្ព័ន្ធអង្គការកូសេកាំកាន់តែមានប្រសិទ្ធិភាព?**

គណៈកម្មាការនាយកគួរមានតួនាទីបន្ថែមមួយចំនួនទៀតដូចខាងក្រោម:

- ជំរុញលើកទឹកចិត្តដល់លេខាធិការដ្ឋាន។
- បែងចែកភារកិច្ច និង ការទទួលខុសត្រូវរបស់សមាជិកគណៈកម្មការនាយក។
- ស្វែងរកការគាំទ្រ និងការផ្តល់ការប្រឹក្សាដល់កម្មវិធីតស៊ូមតិ។
- ចូលរួមប្រជុំរាល់៣ខែម្តង។

**២- តើអង្គការសមាជិករបស់សម្ព័ន្ធអង្គការសេកាំគួរមានតួនាទីអ្វីខ្លះបន្ថែមទៀត ដើម្បីឱ្យការងាររបស់សម្ព័ន្ធកាន់តែមានប្រសិទ្ធិភាព?**

អង្គការជាសមាជិករបស់សម្ព័ន្ធអង្គការគួរមានតួនាទីបន្ថែមដូចខាងក្រោមៈ

- សមាជិកគួរតែមានឆន្ទៈចូលរួមប្រជុំឱ្យបានទៀងទាត់ហើយយ៉ាងតិចណាស់២ដងក្នុង ១ ឆ្នាំ។
- សូមកុំឱ្យផ្លាស់ប្តូរអ្នកចូលរួមប្រជុំញឹកញាប់ពេក។
- ប្រធានអង្គការនីមួយៗគួរបញ្ជូនមន្ត្រីមានជំនាញ និង តួនាទីពាក់ព័ន្ធមកចូលរួមប្រជុំ។
- ផ្តល់មតិ និង អនុម័តទៅលើកម្មវិធី ផែនការ និងយុទ្ធសាស្ត្រសំរាប់ឆ្នាំថ្មី។

***<u>សំណូមពរ:</u> សុំឱ្យមានរបាយការណ៍សកម្មភាព និងប្រចាំឆមាសព្រោះថាបណ្តាញត្រូវដឹងដើម្បីងាយធ្វើការងារ។***

**៣- តើអនុគណៈកម្មការរបស់កម្មវិធីគួរមានតួនាទីអ្វីបន្ថែមទៀត ដើម្បីឱ្យការងាររបស់កម្មវិធីកាន់តែមានប្រសិទ្ធិភាព?**

អនុគណៈកម្មការគួរមានតួនាទីបន្ថែមដូចខាងក្រោមៈ

- ចូលរួមរៀបចំសំណើរកម្មវិធី និងថវិកាដាក់ជូនទៅលេខាធិការដ្ឋានដើម្បីសុំយោបល់។
- ចូលរួមធ្វើរបាយការណ៏របស់អនុគណៈកម្មការទៅអង្គការជាសមាជិក។
- ចូលរួមក្នុងការជ្រើសរើសបុគ្គលិក។
- ចូលរួមប្រជុំរៀងរាល់ ២ ឬ ៣ ខែម្តងក្នុងមួយឆ្នាំ។

***<u>សំណូមពរ:</u> សម្ព័ន្ធអង្គការកូសេកាំគួរតែសំរបសំរួលរវាងអនុគណៈកម្មការ និងគណៈកម្មការនាយកជួបពិភាក្សាគ្នារាល់ ៣ ខែម្តង។***

**៤- តើអង្គការជាសមាជិកមានឧបសគ្គអ្វីខ្លះក្នុងការសហការណ៏ជាមួយសម្ព័ន្ធអង្គការកូសេកាំ?**

ឧបសគ្គរបស់អង្គការជាសមាជិកក្នុងការសហការជាមួយសម្ព័ន្ធអង្គការកូសេកាំមានដូចខាងក្រោមៈ

- ប្រជុំញឹកញាប់ពេកដែលធ្វើឱ្យអង្គការជាសមាជិកចំណាយធនធានមនុស្ស និងពេលវេលាច្រើន
- ប្រព័ន្ធទំនាក់ទំនងពតិមាននៅមានក៏រិត  អង្គការជាសមាជិកនៅខេត្តមួយចំនួនមិនមានប្រព័ន្ធសារអេឡិចត្រូនិច។
- របៀបវារៈប្រជុំពេលខ្លះមិនទាក់ទងទៅការងាររបស់អង្គការជាសមាជិក។
- មិនសូវទទួលបានពតិមាន និង របាយការណ៏គ្រប់គ្រាន់ពីសម្ព័ន្ធ។

***<u>សំណូមពរ:</u>***

- សូមផ្តល់ដំណឹងយ៉ាងតិចមួយសប្តាហ៍មុនពេលប្រជុំ។
- សូមសម្ព័ន្ធធ្វើផែនការប្រចាំឆ្នាំអំពីកាលបរិច្ឆេទប្រជុំអោយបានច្បាស់ជាមុនដើម្បីងាយស្រួលកុំឱ្យធ្វើផែនការជាន់ពេលគ្នា។

## IV- ផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០០៦

### ១- កម្មវិធីតស៊ូមតិ

**គោលបំណង:**

សំរាប់ផែនការយុទ្ធសាស្ត្រក្នុងឆ្នាំ ២០០៦នេះ គឺមានគំរោងចំនួន ៤ ដែលត្រូវធ្វើដោយផ្តោតលើគុណភាពជាជាងបរិមាណទៅលើការតស៊ូមតិរកយុត្តិធម៌ដល់ជនរងគ្រោះ ដោយសារការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភសេពសន្ថវៈទៅលើកុមារនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាធ្វើអន្តរាគមន៍ទៅស្ថាប័នដែលពាក់ពន្ធ័ក្នុងការរកដំណោះស្រាយដែលសមស្រប និងប្រកបដោយប្រសិទ្ធិភាពតាមរយៈកិច្ចពិភាក្សាតុមូលជាមួយរដ្ឋាភិបាល និងភ្នាក់ងារអន្តរជាតិ ។

**កម្មវិធីនេះត្រូវធ្វើដោយផ្តោតលើវិស័យបីជាចំបងគឺ ផ្នែកច្បាប់ ផ្នែកសង្គម និងការផ្តល់ការគាំទ្រលើកទឹកចិត្តដល់កុមាររងគ្រោះ ដែលរួមមានសកម្មភាពដូចខាងក្រោម:**

១- គំរោងកិច្ចពិភាក្សាតុមូលដើម្បីស្វែងរកការឯកភាពគ្នាលើបញ្ហា និងយុទ្ធសាស្ត្រទប់ស្កាត់ការរំលោភបំពានលើកុមារនៅកម្ពុជា ។

២- គំរោងកាត់បន្ថយការរំលោភសេពសន្ថវៈលើកុមារ ។

៣- គំរោងផ្តល់ការគាំទ្រ និងផ្តល់អំណាចដល់ជនរងគ្រោះ ។

៤- គំរោងវិធានការណ៍ការពារកុមាររងគ្រោះ ។

**សំនួរពិភាក្សា**

**១- តើអ្នកយល់ស្របទេដែលសម្ព័ន្ធអង្គការកូសេកាំ ផ្តោតអារម្មណ៍ទៅលើការតស៊ូមតិ លើផ្នែកទាំងបី គឺផ្នែកច្បាប់ ផ្នែកសង្គម និង ការគាំទ្រលើកទឹកចិត្តដល់កុមាររងគ្រោះ?**

អ្នកចូលរួមទាំងអស់យល់ស្របចំពោះកម្មវិធីតស៊ូមតិរបស់សម្ព័ន្ធអង្គការកូសេកាំ ប៉ុន្តែកូសេកាំត្រូវផ្សព្វផ្សាយ និងអញ្ជើញអង្គការជាសមាជិក និងក្រុមអ្នកច្បាប់ឱ្យចូលរួមក្នុងក្រុមការងារដើម្បីពិភាក្សាពីគោលបំណង និងផលប្រយោជន៍នៃការតស៊ូមតិលើផ្នែកទាំងបីនេះ ។

**២- តើសម្ព័ន្ធអង្គការកូសេកាំគួរធ្វើយ៉ាងណាដើម្បីជំរុញការចូលរួមរបស់អង្គការជាសមាជិកនៅក្នុងកម្មវិធីតស៊ូមតិទាំងបីផ្នែកខាងលើ?**

ដើម្បីបង្កើនការចូលរួមរបស់សមាជិកសម្ព័ន្ធនៅក្នុងការងារតស៊ូមតិរបស់សម្ព័ន្ធអង្គការកូសេកាំទាំងបីផ្នែកខាងលើ គឺត្រូវ:

- សម្ព័ន្ធអង្គការកូសេកាំត្រូវធ្វើការសហការណ៍ជាមួយអង្គការដែលមានសក្តានុពល ដើម្បីធ្វើការទាក់ទាញការចូលរួមអោយបានទៀងទាត់ ។
- ការប្រជុំរួមត្រូវមានពេលវេលាសមរម្យ និងពិភាក្សាឱ្យចំទិសដៅ ។
- របៀបវារៈនៃការប្រជុំសូមឱ្យគ្របដណ្តប់ ឬទាក់ទងនឹងផលប្រយោជន៍របស់អង្គការសមាជិក ។
- អញ្ជើញប្រធានអង្គការជាសមាជិកឱ្យចូលរួមបង្ហាញពីឆន្ទះចូលរួមក្នុងដំណើរការតស៊ូមតិ ។
- អង្គការជាសមាជិកត្រូវចាត់តាំងបុគ្គលិកណាម្នាក់ដែលមានជំនាញពាក់ព័ន្ធចូលរួមក្នុងការងារតស៊ូមតិ ។
- បង្កើតអនុសារណៈយោគយល់គ្នាស្តីពីការសហការណ៍រវាងសម្ព័ន្ធអង្គការកូសេកាំ និងអង្គការជាសមាជិក ។
- ជ្រើសរើស តែងតាំងប្រធានដឹកនាំក្រុមការងារឱ្យមានកាលកំណត់ និងប្តូរវេនគ្នា ។
- សម្ព័ន្ធអង្គការកូសេកាំគួររៀបចំផែនការជាមួយអង្គការជាសមាជិកជាមុនសិន មុននឹងអញ្ជើញអង្គការសមាជិកទាំងអស់ចូលរួម ។
- សូមសម្ព័ន្ធអង្គការកូសេកាំផ្តល់ពតិមានពីការចូលរួមរបស់កុមារ និងរបៀបវារៈមុននឹងអញ្ជើញកុមារទៅចូលរួមការប្រជុំ និងផ្តល់ពីលទ្ធផលនៃការចូលរួមរបស់កុមារដល់សាម៉ីអង្គការ ។
- ក្រុមសំរបសំរួលគួរផ្តល់ឱ្យអនុគណៈកម្មាការ (Sub-Committee) នូវការទទួលខុសត្រូវទៅលើផែនការសកម្មភាពនៃក្រុមកុមារតស៊ូ (Girl Speak-out).

**សំណួរ. តើសម្ព័ន្ធអង្គការកូសេកាំធ្វើយ៉ាងណាដើម្បីកាត់បន្ថយការរំលោភលើកុមារ?**

ដោយសារក្រុមការងារនេះទើបបង្កើត នោះផែនការយុទ្ធសាស្ត្រនឹងត្រូវរៀបចំនៅខែមករា ឆ្នាំ២០០៦ តាមរយៈកិច្ចពិភាក្សារបស់ក្រុម ។

## ២. កម្មវិធីស្រាវជ្រាវ

កម្មវិធីនេះត្រូវធ្វើដោយផ្តោតលើការសិក្សាពីទេសចរណ៍ផ្លូវភេទលើកុមារ ការសិក្សាពីការកេងប្រវ័ញ្ចពលកម្មកុមារសិក្សាពីទំរង់ផ្សេងៗទៀតដែលដែលពាក់ព័ន្ធ នឹងការកេងប្រវ័ញ្ចលើកុមារដែលរួមមានសកម្មភាពដូចខាងក្រោម:

**១- ការវិភាគពីស្ថានភាពកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា ។**

**២- ការត្រួតពិនិត្យលើបទអន្តរាគមន៍ដើម្បីដោះស្រាយបញ្ហាជួញដូរ និងកេងប្រវ័ញ្ចលើកុមារ ។**

**សំនួរពិភាក្សា**

**១- តើលោក លោកស្រី យល់យ៉ាងណាចំពោះកម្មវិធីស្រាវជ្រាវឆ្នាំ ២០០៦?**

កម្មវិធីស្រាវជ្រាវរបស់សម្ព័ន្ធអង្គការកូសេកាំឆ្នាំ២០០៦ពិតជាមានប្រយោជន៍ព្រោះផ្តល់នូវទិន្នន័យក្នុងការធ្វើផែនការសំរាប់អង្គការនីមួយៗ និង ពតិមានថ្មីៗបន្ថែមទៀតដល់អង្គការជាសមាជិក ។

**២-តើគំរោងនិមួយៗនៃកម្មវិធីស្រាវជ្រាវឆ្លើយតបទៅកម្មវិធីតស៊ូមតិយ៉ាងណាខ្លះ?**

តាមរយៈការស្រាវជ្រាវគឺ ធ្វើអោយមានគំនិត និងភស្តុតាងច្បាស់លាស់ដើម្បីធ្វើការតស៊ូមតិឱ្យមានប្រសិទ្ធិភាពតាមរយៈ

- ផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៏ស្រាវជ្រាវ ដល់អង្គការ និងស្ថាប័នដែលពាក់ព័ន្ធ ។
- លទ្ធផលដែលបានមកពីការស្រាវជ្រាវគឺជាអនុសាសន៏សំរាប់ធ្វើផែនការ ។
- បង្ហាញឱ្យដឹងពីពតិមានពិតរបស់ជនរងគ្រោះ និងការផ្លាស់ប្តូររបស់គេ ។

**៣- តើកម្មវិធីស្រាវជ្រាវរបស់សម្ព័ន្ធអង្គការកូសេកាំឆ្នាំ ២០០៦ ផ្តល់ផលប្រយោជន៏អ្វីខ្លះដល់អង្គការជាសមាជិក?**

កម្មវិធីស្រាវជ្រាវរបស់សម្ព័ន្ធអង្គការកូសេកាំឆ្នាំ ២០០៦ ផ្តល់ផលប្រយោជន៏ដល់អង្គការជាសមាជិកដូចជា:

- ចែករំលែកពតិមានគ្នាទៅវិញទៅមក ពីតំបន់មួយទៅតំបន់មួយរួមទាំងសកម្មភាពការងារផង ។
- លទ្ធផលយកទៅធ្វើផែនការយុទ្ធសាស្ត្រ និងជាការអនុវត្តជាក់ស្តែងផងដែរ ។
- អង្គការសមាជិកអាចធ្វើផែនការសកម្មភាពតាមអនុសាសន៏ ឬធ្វើសំណើរកថវិកាសំរាប់អង្គការ ។
- ចូលរួមជាកំលាំងជាមួយសម្ព័ន្ធអង្គការកូសេកាំ ធ្វើការតស៊ូមតិប្រកបដោយប្រសិទ្ធិភាពក្នុងការអន្តរាគមន៏ជួយដល់កុមារ និងជនរងគ្រោះ ។

***សំណូមពរ:***

- សូមអោយសម្ព័ន្ធអង្គការកូសេកាំធ្វើការសិក្សានៅតាមខេត្ត ដែលទាក់ទងទៅនឹងការរំលោភផ្លូវភេទ និងការកេងប្រវ័ញ្ច ពលកម្មកុមារ ។
- ពេលសម្ព័ន្ធអង្គការកូសេកាំធ្វើការស្រាវជ្រាវគួរសុំយោបល់ទៅសមាជិកផង អំពីប្រធានបទដើម្បីចែករំលែក បទពិសោធន៏ និងទិន្នន័យដែលជាប្រយោជន៏ក្នុងការធ្វើគំរោង ។

## ៣. កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD)

ផែនការសកម្មភាពរបស់កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD) មានដូចខាងក្រោមៈ

**សកម្មភាពដែលត្រូវធ្វើ:**

- កម្មវិធីចំរុះដើម្បីដោះស្រាយបញ្ហាកុមារ ។
- កម្មវិធីបណ្តុះបណ្តាលផ្នែកគ្រប់គ្រង ។
- កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស ។

**១- តើលោក លោកស្រី មានសំណូមពរអ្វីខ្លះ ដើម្បីអោយការងាររបស់សម្ព័ន្ធកូសេកាំកាន់តែមានប្រសិទ្ធិភាព?**

ដើម្បីអោយការងារកាន់តែមានប្រសិទ្ធិភាពសម្ព័ន្ធអង្គការកូសេកាំគួរតែ:

- រៀបចំតំណាងជនបង្គោល (Focal Point Network) នៅតាមខេត្តនីមួយៗ ដើម្បីឱ្យពួកគាត់បានដឹកនាំការប្រជុំ /ពិភាក្សាពីការងារដែលពាក់ព័ន្ធ និងកុមារ ។
- មន្ត្រីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD) ដើរតួនាទីជាអ្នកសំរបសំរួល និងផ្តួចផ្តើមអង្គការសាមីដែលបញ្ជូនមន្ត្រីតំណាងឱ្យមកចូលរួមក្នុងការប្រជុំត្រូវឱ្យមានសិទ្ធិក្នុងការសំរេចចិត្ត

**២- តើលោក លោកស្រី ចង់អោយសម្ព័ន្ធអង្គការកូសេកាំមានសកម្មភាព ឬយុទ្ធសាស្ត្រអ្វីខ្លះបន្ថែមទៀតដើម្បីជួយបង្កើនកិច្ចសហការរវាងអង្គការដែលពាក់ព័ន្ធទាំងអស់ជាមួយកូសេកាំអោយកាន់តែល្អ?**

ដើម្បីបង្កើនការសហការណ៏ជាមួយអង្គការដែលពាក់ព័ន្ធសម្ព័ន្ធអង្គការកូសេកាំគួរតែ:

- លើកទឹកចិត្តឱ្យអង្គការសមាជិកធ្វើកិច្ចការដូចជាជំរុញឱ្យធ្វើការតស៊ូមតិនៅថ្នាក់ខេត្ត ដែលគាំទ្រដោយសម្ព័ន្ធអង្គការកូសេកាំ ។
- បង្កើតប្រព័ន្ធផ្សព្វផ្សាយពតិមានឱ្យបានទាន់ពេលដល់សមាជិក ។
- បង្កើតឯកសាររួមគ្នាជាមួយអង្គការសមាជិកដើម្បីជាការលើកទឹកចិត្ត ដូចជាការបញ្ចូលសកម្មភាពរបស់អង្គការជាសមាជិក ។
- ពង្រឹងការងារដែលមានស្រាប់ និងធ្វើការងារដែលមិនទាន់បានបំពេញ ។

***សំណូមពរ:***

- ផ្លាស់ប្តូរទីកន្លែងប្រជុំ ។
- ដើរតួនាទីជាអ្នកសំរបសំរួលប្រកបដោយប្រសិទ្ធភាព ។

## ៤~ កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្មនៅក្នុងសហគមន៍

***សកម្មភាពដែលត្រូវធ្វើ:***

១- គំរោងមូលនិធិអាហារូបករណ៍សំរាប់ជនរងគ្រោះដោយការជួញដូរ ។

២- គំរោងគាំទ្រវគ្គបណ្តុះបណ្តាល និង សមាហរណកម្ម ។

៣- គំរោងសំរបសំរួលការគ្រប់គ្រងករណីជនរងគ្រោះដោយការជួញដូរ ។

## សំណួរពិភាក្សាផ្នែកសមាហរណកម្ម

**១- តើកុមារដែលរស់នៅក្នុងមណ្ឌលបានធ្វើសមាហរណកម្មប្រកបដោយ ជោគជ័យសំរាប់រយៈពេលមួយឆ្នាំ ឬយូរឆ្នាំគិតជាមធ្យមមានប៉ុន្មានភាគរយ?**

**ក. ≤២៥% ខ. ≤៥០% គ. ≤៧៥% ឃ. ≥៧៥%**

បើគិតជាមធ្យមជាភាគរយនៃកុមារដែលរស់នៅក្នុងមណ្ឌលដែលត្រូវបានធ្វើសមាហរណកម្មដោយជោគជ័យសំរាប់រយៈពេលមួយឆ្នាំ ឬយូរឆ្នាំនៅមានក៏រិតនៅឡើយ ដែលក្រុមពិភាក្សាទាំងបីទទួលបានបទពិសោធន៍ផ្សេងៗគ្នា ដែលក្រុមនិមួយៗ លើកឡើងដូចខាងក្រោម:

ក្រុម១: លទ្ធផលតិចជាង ៥០%

ក្រុម២: លទ្ធផលតិចជាង ៧៥%

ក្រុម៣: លទ្ធផលច្រើនជាង ៧៥%

**២- ដើម្បីអោយការងារសមាហរណកម្មប្រកបដោយជោគជ័យ តើអង្គការក្រៅរដ្ឋាភិបាលគួរធ្វើយ៉ាងណាក្នុងចំណោមចំលើយខាងក្រោមនេះ? តើហេតុអ្វី?**

ក- គួរអង្គការក្រៅរដ្ឋាភិបាលធ្វើដោយខ្លួនឯង ។

ខ- គួរមានគំរោងពិសេសមួយ ។

គ- គួរអង្គការក្រៅរដ្ឋាភិបាលរួមគ្នាសហការ ។

ដើម្បីអោយការធ្វើសមាហរណកម្មអតិថិជនប្រកបដោយជោគជ័យ អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធទាំងអស់គួររួមសហការគ្នាព្រោះ:

- អង្គការខ្លះទទួលកុមារអោយស្នាក់នៅបានតែរយៈពេលខ្លី ដែលអតិថិជនរៀនជំនាញមិនបានចប់សព្វគ្រប់ ។
- មណ្ឌលរបស់អង្គការខ្លះខ្វះជំនាញផ្តល់ដល់អតិថិជន ។

- ដើម្បីអោយអតិថិជនងាយទទួលបានសេវាកម្ម ។

**៣- តើសម្ព័ន្ធអង្គការកូសេកាំ គួរតែមានគំនិតផ្តួចផ្តើមអោយមានទូវគំរោងសមាហរណកម្មរួមគ្នាជាមួយភ្នាក់ងារដទៃទៀតដែរឬទេ? បើគួរតើសម្ព័ន្ធអង្គការកូសេកាំជាអ្នកដឹកនាំគំរោងផ្ទាល់ ឬគ្រាន់តែធ្វើតាមភ្នាក់ងារដទៃទៀតដូចជាអង្គការ IOM/UNICEF? តើសម្ព័ន្ធអង្គការកូសេកាំគួរតែចូលរួមក្នុងគំរោងសមាហរណកម្មដោយរបៀបណា?**

សម្ព័ន្ធកូសេកាំគួរមានគំនិតផ្តួចផ្តើមអោយមានគំរោងសមាហរណកម្មរួមគ្នា ជាមួយភ្នាក់ងារដទៃទៀតដោយៈ

- សម្ព័ន្ធអង្គការកូសេកាំគួរតែធ្វើតាមភ្នាក់ងារដទៃទៀតដូចជាៈ អង្គការ **IOM** ក្រសួងសង្គមកិច្ច និងអង្គការ **UNICEF** ដើម្បីធានាឱ្យមាននិរន្តរភាព និងភាពសហការណ៍គ្នា ។
- សម្ព័ន្ធអង្គការកូសេកាំគួរតែធ្វើការសហការណ៍គ្នាជាមួយគ្រប់អង្គការពាក់ព័ន្ធទាំងអស់ ។

**៤- តាមយោបល់របស់អ្នកតើកូសេកាំគួរកែលំអលើចំនុចណាខ្លះ ដើម្បីអោយគំរោងមូលនិធិអាហារូបករណ៍របស់សម្ព័ន្ធអង្គការកូសេកាំកាន់តែមានភាពប្រសើរថែមទៀត?**

អ្នកសំរបសំរួលកម្មវិធី សមាហរណកម្មរបស់សម្ព័ន្ធអង្គការកូសេកាំ ត្រូវធ្វើការឱ្យជិតស្និទ្ធជាមួយអ្នកសំរបសំរួល គំរោងសមាហរណកម្មតាមមណ្ឌលរបស់អង្គការពាក់ព័ន្ធទាំងអស់ដើម្បីវាយតំលៃទៅរកចំណុចរួមមួយ ។

- សម្ព័ន្ធអង្គការកូសេកាំគួរតែធ្វើការសហការណ៍គ្នាជាមួយក្រសួងសង្គមកិច្ច ដើម្បីតាមដានករណីនិមួយៗ ។
- សម្ព័ន្ធអង្គការកូសេកាំ គួរតែធ្វើការសហការណ៍ ពីតំបន់មួយទៅតំបន់មួយ ។
- គោលការណ៍សមាហរណកម្មតែមួយ ។
- ប្រជុំតាមដានពត៌មានពីសមាហរណកម្មរាល់៣ខែម្តង ។
- ចងក្រងឯកសារពីភាពជោគជ័យ និងបរាជ័យពីការធ្វើសមាហរណកម្ម និងផ្តល់ជូនដល់សមាជិកដែលពាក់ព័ន្ធ ។
- ឱ្យអង្គការសមាជិកនៅក្នុងតំបន់ណាដែលបានបញ្ជូនអតិថិជនធ្វើការតាមដាន និងបិទករណីរបស់អតិថិជន ។

**សំៈ តើសម្ព័ន្ធអង្គការកូសេកាំបានជួយដល់គ្រួសាររបស់អតិថិជនដែរឬទេ?**

សម្ព័ន្ធអង្គការកូសេកាំមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងគ្រួសាររបស់អតិថិជនទាំងមូលទេគឺត្រូវការការសហការណ៏ពីសាមុីអង្គការ ។ ប៉ុន្តែនៅក្នុងគំរោងមូលនិធិបណ្តុះបណ្តាលវិជ្ជាជីវៈក៏បានឧបត្ថម្ភដល់គ្រួសាររបស់ពួកគេចំនួនពី ១៥ ទៅ ៣០ដុល្លារ ក្នុងមួយខែអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង ប៉ុន្តែសំខាន់យើងត្រូវគិតទៅលើអតិថិជនជាមុនសិនបើអតិថិជនមានការងារធ្វើមានប្រាក់ចំណូលដែលអាចសន្សំទុកបានខ្លះជាការចាំបាច់សំរាប់ជំហ៊ានដំបូង ។

**សំៈ តើប្រាក់ចំណូលសមស្របដែល សម្ព័ន្ធអង្គការកូសេកាំកំណត់មានចំនួនប៉ុន្មានក្នុង១ខែសំរាប់អតិថិជនដើម្បីឱ្យអង្គការជាសមាជិកអាចយកជាបទពិសោធន៏តាមបាន?**

ប្រាក់ចំណូលសមស្របដែលសម្ព័ន្ធអង្គការកូសេកាំកំណត់គឺ មិនទាបជាង៣០ដុល្លារក្នុងមួយខែ ដោយមិនគិតពីថ្លៃ អាហារ និងការស្នាក់នៅ ។ ករណីបើគ្មានអាហារនិងការស្នាក់នៅទេគឺពី ៤៥ ទៅ ៥០ដុល្លារ ទើបអាចទទួល យកបាន ដែលនេះគឺជាគោលការណ៏របស់អាហារូបករណ៏ ។

**សំៈ- តាមផ្នែកច្បាប់ តើសម្ព័ន្ធអង្គការកូសេកាំមានកិច្ចសន្យាជាមួយស្ថាប័នណាមួយដែរទេ ដើម្បីធានាថាសម្ព័ន្ធអង្គការកូសេកាំ ពិតជាមិនខុសច្បាប់ទេក្នុងការយកអតិថិជនមករៀន?**

សម្ព័ន្ធអង្គការកូសេកាំគ្រាន់តែជាអ្នកសំរបសំរួលប៉ុណ្ណោះរាល់ការងារ និងភារកិច្ចទាំងឡាយមុននឹងបញ្ជូនអតិថិជនមកសម្ព័ន្ធអង្គការកូសេកាំ គឺជាភារៈកិច្ចរបស់អង្គការសាមុី ។

**សំៈ អតិថិជនដែលរៀននៅ** CCHDO **ចប់ហើយតែពួកគេនៅមិនទាន់មានលទ្ធភាពរកប្រាក់ចំនូលបានដល់៣០ដុល្លារ ក្នុងមួយខែនៅឡើយទេ តើនេះជាកាតព្វកិច្ចរបស់អ្នកណាដែរ?**

- ក្នុងករណីនេះទីមួយអតិថិជនជាអ្នកសំរេចចិត្តដោយខ្លួនឯងថា តើពួកគេគួរនៅធ្វើការងារនៅកន្លែងនោះទៀត ឬចាកចេញទៅរកកន្លែងដែលទទួលបានប្រាក់ច្រើនជាងនេះ ។
- ទីពីរសូមឱ្យអង្គការទាំងអស់ពិនិត្យមើលឡើងវិញនូវអនុសារណៈស្តីពីការយោគយល់ (MOU) ជាមួយនឹងសម្ព័ន្ធអង្គការកូសេកាំក៏ដូចជាបណ្តាអង្គការជាដៃគូទាំងអស់ ។

## សំណួរពិភាក្សាផ្នែកអាហារូបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈ

### ១- មូលហេតុអ្វីបានជាការបណ្តុះបណ្តាលដែលផ្តល់ឱ្យដោយអង្គការមិនអាចរកការងារឱ្យអតិថិជនរបស់ខ្លួនធ្វើបាន ឬបើអាចតែទទួលបានប្រាក់ចំនូលមិនសមស្រប?

មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលផ្តល់ដោយអង្គការ មិនអាចរកការងារអោយអតិថិជនរបស់ខ្លួនធ្វើបាន ឬអាចរកការងារធ្វើបានតែទទួលបានប្រាក់ចំនូលមិនសមស្របព្រោះបណ្តាលមកពីកត្តា ២ ដូចខាងក្រោមៈ

**ក- មណ្ឌលបណ្តុះបណ្តាល និងទីផ្សារការងារៈ**

- រយៈពេលបណ្តុះបណ្តាលមានក៏រិត ។
- ខ្វះឧបករណ៏ទំនើបៗសំរាប់តំរូវតាមតំរូវការទីផ្សារ ។
- ផ្តល់ជំនាញដល់អតិថិជនមិនឆ្លើយតបទៅនឹងចំណង់ចំណូលចិត្តរបស់អតិថិជន តំរូវការទីផ្សារ និងសហគមន៏របស់ពួកគេ ។
- ជំនាញផ្តល់អោយអតិថិជននៅមានក៏រិត ។
- ស្ថាប័នការងារឯកជនមានភាពរើសអើងនិងអតិថិជនមណ្ឌល ។
- លក្ខខណ្ឌរបស់អង្គការកំណត់ច្រើនពេកធ្វើអោយស្ថាប័នការងារឯកជនមិនហ៊ានទទួលយកអតិថិជនអោយធ្វើការងារ ។
- ផលិតផល និងស្នាដៃ មិនតំរូវនឹងតំរូវការទីផ្សារ ។
- ខ្វះការប្រកួតប្រជែង ។

**ខ- អតិថិជនៈ**

- អតិថិជនមានចំណេះដឹងទូទៅទាបរួមនិងសមត្ថភាពការងារនៅមានក៏រិតនិងមិនមានឳកាសចុះហាត់ការ ។
- អតិថិជនមិនមានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមជំនាញដែលខ្លួនចង់រៀន ។
- ជំនាញទទួលបានត្រូវជាមួយទីផ្សារការងារ ប៉ុន្តែអតិថិជនមិនសកម្មជាមួយការងារ ។
- អតិថិជនអវត្តមានការងារ (មិនទៅធ្វើការ ឬឈប់ញឹកញាប់ពេក) ធ្វើឱ្យនិយោជកកាត់ប្រាក់ខែ ។
- អតិថិជនខ្វះដើមទុនបង្កើតមុខរបរ ។
- អតិថិជនមិនមានភាពក្លាហានក្នុងការបង្កើតមុខរបរ ។

**២- បើគិតជាមធ្យម តើអតិថិជនគោលដៅដែលរៀនជំនាញវិជ្ជាជីវៈចំនួនប៉ុន្មានភាគរយដែលអាចមានការងារធ្វើជាមួយប្រាក់ចំនូលសមស្រប?**

**ក- មិនលើសពី ៤០%, ខ- មិនលើសពី ៦០%, គ- មិនលើសពី ៨០%**

* អតិថិជនគោលដៅទាំងអស់ដែលរៀនជំនាញវិជ្ជាជីវៈនៅក្នុងមណ្ឌលបណ្តុះបណ្តាលរបស់អង្គការអាចមានការងារធ្វើជាមួយប្រាក់ចំណូលសមស្របមិនលើសពី ៤០ ភាគរយទេ។

**៣-តើយើងគួរដាក់អោយអតិថិជនរៀននៅកន្លែងណាមួយដែលសមស្របជាងគេ? ហេតុអ្វី?**

**ក- មណ្ឌលរបស់អង្គការ, ខ- សាលាបណ្តុះបណ្តាលវិជ្ជាជីវៈនានា, គ- តាមហាងជំនួញឬសេវាកម្មឯកជន**

ក្នុងការផ្តល់ការបណ្តុះបណ្តាលដល់អតិថិជនយើងគួរអោយអតិថិជនគោលដៅទាំងអស់រៀននៅកន្លែងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរបស់ហាងជំនួញ ឬសេវាកម្មឯកជនគឺសមស្របជាងគេព្រោះ:

- អតិថិជនមានឱកាសអនុវត្តផ្ទាល់។
- មានទីផ្សារការងារធំ។
- អតិថិជនអាចរៀនសូត្រពីម្ចាស់ហាង ឬសេវាកម្មបានច្រើន។

***ប៉ុន្តែសាម៉ីអង្គការរបស់អតិថិជនត្រូវជួយគាំទ្រដល់អតិថិជនដូចខាងក្រោម:***

- ភ្នាក់ងារអង្គការជាអ្នកជួយរកការងារអោយអតិថិជន។
- ភ្នាក់ងារអង្គការចុះតាមដានជាប្រចាំចំពោះការបណ្តុះបណ្តាល និងការធ្វើការងាររបស់អតិថិជន
- សាលាបណ្តុះបណ្តាលវិជ្ជាជីវៈដទៃៗទៀត។

**៤- តាមយោបល់របស់លោក-លោកស្រី តើសម្ព័ន្ធអង្គការកូសេកាំគួរកែលំអលើចំនុចណាខ្លះដើម្បីឱ្យគំរោងមូលនិធិអាហារូបករណ៍ របស់សម្ព័ន្ធអង្គការកូសេកាំកាន់តែមានភាពប្រសើរឡើង?**

ដើម្បីអោយដំណើរការគំរោងមូលនិធិអាហារូបករណ៍សំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈ (VTF) របស់សម្ព័ន្ធអង្គការកូសេកាំ កាន់តែមានប្រសិទ្ធិភាពនោះ សម្ព័ន្ធអង្គការកូសេកាំគួរកែលំអលើចំនុចមួយចំនួនដូចខាងក្រោម:

- គួរបង្កើតជំនាញថ្មីៗបន្ថែមទៀត និងត្រូវតែជួយរកទីផ្សារការងារ ឬទីផ្សារផលិតផល។
- បំប៉នបំណិនជីវិត និងចំណេះដឹងពីសង្គមដល់អតិថិជន។
- កុំពន្យាពេលយូរពេកក្នុងការជួយគាំទ្រផ្នែកសំភារៈ និងថវិកាដល់អតិថិជន និងបញ្ជូនអតិថិជនទៅរៀនជំនាញ។

- ធ្វើយ៉ាងណាជួយអតិថិជនឱ្យចេះសំរបសំរួលខ្លួនទៅតាមលក្ខខណ្ឌរស់នៅជារបៀបសាមញ្ញៗ ។
- ត្រូវឱ្យមានមន្ត្រីជំនាញសំរាប់ពិគ្រោះយោបល់ជាមួយអតិថិជន ។
- គួរផ្តល់ថវិកាខ្លះដើម្បីបង្កើនគុណភាពផលិតផលដល់អង្គការដែលសហការ ។
- ត្រូវតែផ្តល់ដើមទុនខ្លះដល់អតិថិជនសំរាប់ប្រកបមុខរបរ ។

**សំៈ តើយើងធ្វើយ៉ាងណានៅពេលយើងសិក្សាពីទីផ្សារការងារសមស្របហើយផ្តល់ជំនាញដែលមានសក្តានុពលលើទីផ្សារដល់អតិថិជនតែវាផ្ទុយពីស្ថានភាពក្នុងសហគមន៍របស់ពួកគេ?**

ការធ្វើសមាហរណកម្មរបស់កម្មវិធី VTF មានន័យថាការបញ្ជូនអតិថិជនទៅកន្លែងណាដែលពួកគេអាចមានការងារធ្វើឬប្រកបរបរបានកំរៃសមស្របដោយមិនគិតថាជាសហគមន៍ដើមឬកន្លែងណានោះឡើយ ។

## សេចក្តីសន្និដ្ឋាន

សិក្ខាសាលារយៈពេលពីរថ្ងៃស្តីពីការបង្ហាញសមិទ្ធផលនៃកម្មវិធីនិមួយៗក្នុងឆ្នាំកន្លងមក និង ផែនការសកម្មភាពសំរាប់ឆ្នាំបន្តយើងទទួលបានលទ្ធផលល្អគួរជាទីមោទនៈដោយ សមាជិកអង្គការសម្ព័ន្ធដែលបានចូលរួមទាំងអស់ខិតខំប្រឹងប្រែង ចែករំលែកបទពិសោធន៍ ផ្តល់អនុសាសន៍ និងមតិយោបល់ល្អៗប្រកបដោយភាពស្ថាបនា តាមរយៈការពិភាក្សាជាក្រុម ក៏ដូចជាក្នុងវេទិកាសំនួរចំលើយ ។

ជាលទ្ធផលយើងឃើញថា មិនមានការកែប្រែគួរអោយកត់សំគាល់ទៅលើកម្មវិធីនិមួយៗរបស់សម្ព័ន្ធអង្គការទេគឺ គ្រាន់តែមានអនុសាសន៍មួយចំនួនសំរាប់កែលំអលើការអនុវត្តកម្មវិធីទាំងនោះនៅថ្ងៃខាងមុខ ។ ហើយម៉្យាងទៀតសមាជិកសម្ព័ន្ធអង្គការកូសេកាំសំដែងនូវភាពស្និទ្ធស្នាល និងកិច្ចសហការណ៏ដើម្បីសំរេចគោលដៅរួមក្នុងការដោះស្រាយបញ្ហាជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏នៅមានចំណុចខ្វះខាតខ្លះដែរ ដោយសារតែអ្នកចូលរួមជាតំណាងអង្គការសមាជិកខ្លះមិនមែនជាថ្នាក់ដឹកនាំដែលការសំរេចចិត្តរបស់គាត់នៅមានកំរិត និងមានអវត្តមានរបស់អង្គការសមាជិកមួយចំនួនតូចដែលធ្វើអោយការពិភាក្សាមិនទាន់មានភាពទូលំទូលាយនៅឡើយ ។

ជាការសន្និដ្ឋានលទ្ធផលសិក្ខាសាលាដែលយើងទទួលបាននេះអាចបំរើផលប្រយោជន៏រួមក្នុងការអភិវឌ្ឍន៏កម្មវិធីរបស់អង្គការជាសមាជិក និងសម្ព័ន្ធអង្គការកូសេកាំ ។

## ឧបសម្ព័ន្ធទី១:

## លទ្ធផលវាយតំលៃសម្ព័ន្ធអង្គការកូសេកាំ

លោក ទូន វិចិត្រ ប្រធានសម្ព័ន្ធអង្គការកូសេកាំ បានសង្ខេបពីរបាយការណ៍វាយតំលៃលើការងាររបស់សម្ព័ន្ធអង្គការកូសេកាំរយៈពេលកន្លងមកនៅខែ កក្កដា ឆ្នាំ ២០០៥ ដើម្បីអោយអ្នកចូលរួមជាអង្គការសមាជិកទាំងអស់បានជ្រាបមានដូចខាងក្រោម:

១- លេខាធិការដ្ឋានមានតួនាទីជាអ្នកសំរបសំរួលការងារ ជាអ្នកអនុវត្តគំរោងធ្វើសកម្មភាព និងអ្នកចូលរួមសំរេចចិត្តលើការងារជាច្រើនរបស់សម្ព័ន្ធ។ បញ្ហាលំបាកដែលលេខាធិការដ្ឋានជួបប្រទះគឺថាសម្ព័ន្ធអង្គការកូសេកាំមិនដូចជាអង្គការដទៃទៀតទេ ដែលមានម្ចាស់ជំនួយផ្ទាល់ផ្តល់មូលនិធិឱ្យច្រើន និងមានពេលវេលារបស់គេច្បាស់លាស់ ។

២- ទីប្រឹក្សាមានតួនាទី ជាអ្នកផ្តល់ប្រឹក្សាទៅលើគំរោងកម្មវិធី ជាអ្នកផ្តួចផ្តើមគំនិតជួយរកថវិកា និងធ្វើការទំនាក់ទំនងនៅក្នុងប្រទេសនិងក្រៅប្រទេស។

៣- គណៈកម្មការនាយកមានតួនាទី ជាអ្នកផ្តល់ប្រឹក្សា ណែនាំពីទិសដៅ និងគោលនយោបាយកម្មវិធីដែលដូចជាយានមួយដើម្បីសំរេចនូវសកម្មភាពការងារជាក់លាក់។

៤- អង្គការសមាជិកមើលឃើញអត្ថប្រយោជន៍នៃការចូលជាសមាជិកក្នុងសម្ព័ន្ធក្នុងគោលបំណងពីរផ្សេងគ្នាគឺ:

ក. លេខាធិការដ្ឋានអាចជាអ្នកធានាសំរាប់សាម៉ីអង្គការក្នុងការដាក់សំណើទៅម្ចាស់មូលនិធិ និងទទួលការកសាងសមត្ថភាពនានា។

ខ. លេខាធិការដ្ឋានជាអ្នកបំពេញសកម្មភាព និងព្រឹត្តិការណ៍ណាមួយក្នុងគោលបំណងរួម។

៥- ទាក់ទងនឹងការងារជាមួយអង្គការអ៊ិកផាត (ECPACT) ជាទូទៅតែងមានគំរោងធ្វើការស្រាវជ្រាវជាន់ការងារគ្នា។ អ៊ិកផាត (ECPACT) មានតួនាទីជាអ្នកតាមដានលើការងារលុបបំបាត់ការជួញដូរកុមារ។

៦- ជាមួយអង្គការយូនីសេហ្វវិញ (Unicef) គឺកូសេកាំជាអ្នកផ្តួចផ្តើមគំនិតឱ្យមានពង្រាងបទដ្ឋានអប្បបរមាហើយដែលបានក្លាយទៅជារចនាសម្ព័ន្ធមួយរបស់ក្រសួងសង្គមកិច្ចនាពេលបច្ចុប្បន្ននេះ។

## អនុសាសន៍

សម្ព័ន្ធអង្គការកូសេកាំត្រូវតែផ្តោតអារម្មណ៍ខ្លាំងទៅលើកម្មវិធីតស៊ូមតិ និងកម្មវិធីស្រាវជ្រាវ ប៉ុន្តែឧបសគ្គនោះគឺ កង្វះថវិកាសំរាប់ដំណើរការកម្មវិធី។ នៅក្នុងឆ្នាំ២០០៦ស្ថានទូតអង់គ្លេសនឹងផ្តល់មូលនិធិជាង

១០.០០០ដុល្លារ សំរាប់កម្មវិធីតស៊ូមតិ។ ចំណែកកម្មវិធីអភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្សគឺ ជាកម្មវិធីមួយត្រូវការថវិកាច្រើន ដែរដើម្បីដំណើរការវគ្គបណ្តុះបណ្តាល ព្រោះយើងត្រូវចំណាយច្រើនលើថ្លៃគ្រូបណ្តុះបណ្តាល ថ្លៃធ្វើដំណើរ ស្នាក់នៅ អាហារ និង សំភារៈសិក្សាសំរាប់សិក្ខាកាម ហើយបើយើងទៅរៀននៅសាលាក៏ត្រូវចំណាយបង់ថ្លៃសាលាច្រើនដែរ។ ចំពោះគំរោងថវិកាសំរាប់កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្សសំរាប់រយៈពេល ៣ឆ្នាំគឺ មានចំនួនជាង ១០០.០០០ដុល្លារ។ ចំណែកកម្មវិធីស្តានីតិសម្បទា និងសមាហរណកម្ម សម្ព័ន្ធអង្គការកូសេកាំបានទទួលមូលនិធិច្រើនពីមូលនិធិអាស៊ី សំរាប់ដំណើរការគំរោងកម្មវិធីរយៈពេល ៣ឆ្នាំ មានចំនួនជាង ៣០០.០០០០ ដុល្លារ ដែលក្នុងមួយឆ្នាំៗ គំរោងចំណាយយ៉ាងតិចជាង ១០០.០០០ ដុល្លារ។

## ការតាមដានមើលក្រោយពេលវាយតំលៃ:

បន្ទាប់ពីទទួលបានលទ្ធផលនៃការវាយតំលៃ សម្ព័ន្ធអង្គការកូសេកាំបានរៀបចំការប្រជុំមួយជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីចែកលទ្ធផលនេះឱ្យអ្នកពាក់ព័ន្ធទាំងអស់បានអាននឹងផ្តល់ជាមតិយោបល់ (Feedback) ក្នុងនោះមានបុគ្គលិកសម្ព័ន្ធអង្គការកូសេកាំ អនុគណៈកម្មការទាំងបួន និងចុងក្រោយគឺ ជាមួយគណៈកម្មការនាយក ដើម្បីឆ្លងលើពង្រាងវាយតំលៃនេះ ហើយជាលទ្ធផលយើងទទួលបាននូវយោបល់ដូចខាងក្រោម:

១. ត្រូវផ្ទៀងផ្ទាត់ឡើងវិញនូវពង្រាងវាយតំលៃនេះទៅនឹងឯកសារយោងនៃការវាយតំលៃ។

២. ត្រូវរៀបចំនូវលិខិតឆ្លើយតបមួយក្នុងនាមលេខាធិការដ្ឋានដោយប្រមូលផ្តុំនូវការផ្តល់មតិផ្សេងៗពីគណៈកម្មការនាយក អនុគណៈកម្មការក៏ដូចជា បុគ្គលិកទាំងអស់ ហើយផ្ញើជូនទៅអ្នកវាយតំលៃ និងម្ចាស់ជំនួយផងដែរដោយភ្ជាប់ជាមួយឯកសារពង្រាងទី១។

៣. លេខាធិការដ្ឋាន គួរតែរៀបចំសកម្មភាពធ្វើរបាយការណ៍ជំរឿនមួយជូនអង្គការជាសមាជិកអំពីដំណើរការសកម្មភាពដែលអនុវត្តបានរាល់១ខែម្តង បើអាចធ្វើទៅបាន។

៤. សំរបសំរួលឱ្យមានភាពជិតស្និទ្ធរវាង គណៈកម្មការនាយក និងលេខាធិការដ្ឋាន ដើម្បីស្វែងយល់ការងារគ្នាទៅវិញទៅមកតាមរយៈការធ្វើការជាមួយគ្នាមួយសប្តាហ៍មួយថ្ងៃតែករណីនេះមិនអាចទៅរួចទេដោយ ហេតុថា គណៈកម្មការនាយករវល់ពេកដូច្នេះយោងតាមការពិភាក្សាគ្នាគឺសុំត្រឹមថា ឱ្យលេខាធិការដ្ឋាន ជួបពិភាក្សា ហើយធ្វើរបាយការណ៍ទៅប្រធានគណៈកម្មការនាយកវិញ។

# ឧបសម្ព័ន្ធទី២:
# ច្បាប់ និង កុមារ នៅប្រទេសកម្ពុជា

លោក **សុក សំអឿន** បានបង្ហាញពីប្រធានបទ ស្តីពី "ច្បាប់ និងកុមារ" ដើម្បីអោយអង្គការជាសមាជិក ដែលធ្វើការងារពាក់ព័ន្ធនឹងកុមារទាំងអស់បានគិតអំពីបញ្ហាច្បាប់ក្នុងការដោះស្រាយរាល់បញ្ហា។ ជាពិសេសអំពីច្បាប់ព្រហ្មទ័ណ្ឌយើងឃើញថា ច្បាប់នេះមិនមានចែងច្បាស់លាស់ពីការកំណត់អាយុ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារនៅឡើយ ហើយដែលបញ្ហានេះបានធ្វើឱ្យតុលាការមានការលំបាកក្នុងការសំរេចដាក់ទោសទៅលើកុមារដែលមានអាយុក្រោម ១៣ឆ្នាំ ឱ្យមានទោសព្រហ្មទណ្ឌឬលើកលែងទោសកុមារទាំងស្រុងនៅឡើយទេ។

## កុមារ និង ច្បាប់បច្ចុប្បន្ន

- មិនមានចែងពីអាយុទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។
- តើកុមារមានអាយុប៉ុន្មាន ដែលអាចមានទោសជាប់ពន្ធនាគារ ឬ ទទួលខុសត្រូវព្រហ្មទណ្ឌ?
- នៅប្រទេសមួយចំនួនគេកំណត់អាយុក្រោម ១៣ឆ្នាំ គ្មានទោសព្រហ្មទណ្ឌទេ។
- តើកុមារដែលធ្វើខុសសុទ្ធតែត្រូវទទួលទណ្ឌកម្មដាក់ពន្ធនាគារ ឬ គួរមានវិធានការអប់រំផ្សេងទៀត?
- សព្វថ្ងៃនេះ ចៅក្រមម្នាក់ៗអាចកាត់ក្តីគ្រប់រឿងក្តី រួមទាំងកុមារផង។
- តុលាការមាននីតិវិធីតែមួយ មិនថារឿងក្តីឧក្រិដ្ឋ មជ្ឈឹម មនុស្សពេញវ័យ ឬ កុមារនោះទេ។
- នៅប្រទេសថៃ មានីតិវិធីពិសេសសំរាប់កុមារ មានចៅក្រមមានបទពិសោធន៍ និងច្រើននាក់។

## កុមារ និង ប្រព័ន្ធពន្ធនាគារ

- កុមារ និង មនុស្សធំត្រូវគេដាក់នៅក្នុងបន្ទប់ ជាមួយនឹងគ្នា។
- គ្មានកម្មវិធីអប់រំឱ្យបានត្រឹមត្រូវ។
- កុមារដែលជាប់ពន្ធនាគារមិនបានបន្តការរៀនសូត្រនោះទេ។

### ការផ្តល់នីតិសម្បទាកុមារ និង ច្បាប់

- តើការបង្ខំកុមារឱ្យរស់នៅក្នុងមណ្ឌល ជាការត្រឹមត្រូវស្របច្បាប់ដែរឬទេ?
- តើកុមារដែលប្រើប្រាស់ថ្នាំញៀន ត្រូវមានទោសព្រហ្មទណ្ឌដែរឬទេ?
- កុមារព្រមរស់នៅក្នុងមណ្ឌល ប៉ុន្តែឪពុកម្តាយរបស់គេត្រូវការកុមារដើម្បីជួយធ្វើការគាត់ តើត្រូវដោះស្រាយយ៉ាងណា?

## កុមារ និង ច្បាប់ជួញដូរ

- តើសមាជិកសម្ព័ន្ធអង្គការកូសេកាំ ដែលជួបប្រទះរឿងក្តីធំៗដែលត្រូវការសម្ព័ន្ធអង្គការកូសេកាំជួយធ្វើអន្តរាគមន៍ជាក្រុមដែរទេ?
- បើមានរឿងបែបនោះ តើសម្ព័ន្ធអង្គការកូសេកាំគួរមានតួនាទីអ្វីខ្លះ?
- តើសមាជិកឯទៀតអាចជួយសមាជិកគ្នាឯងបានយ៉ាងដូចម្តេច?

## កុមារ និង ច្បាប់ការងារ

- តើនៅកម្ពុជាមានការកេងប្រវ័ញ្ចពលកម្មកុមារហើយឬនៅ?
- ការជួញដូរកុមារឱ្យទៅធ្វើជាអ្នកសុំទាន នៅបរទេស មិនទាន់ចាត់ទុកជាបទល្មើសនៅឡើយទេ ។
- តើយើងចង់ទុកបញ្ហាទាំងនេះអោយនៅដដែល?

# អនុសាសន៍

## បញ្ចូលទៅក្នុងច្បាប់រចនាសម្ព័ន្ធតុលាការ

- សូមបង្កើតឱ្យមានតុលាការកុមារ ឬ តុលាការគ្រួសារ ។
- តុលាការគ្រួសារ ឬ តុលាការកុមារត្រូវជាបុគ្គលដែលមានគ្រួសារ ហើយ និង ទទួលការហ្វឹកហ្វឺនពិសេស ។

## បញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌ

- កំណត់អាយុទទួលខុសត្រូវព្រហ្មទណ្ឌទៅក្នុងច្បាប់ ( ឃើញមានបញ្ចូលហើយ) ។
- កុមារដែលមានអាយុលើសពី ១៣ ដល់ ១៨ ដែលមានទោសព្រហ្មទណ្ឌត្រូវដាក់ទៅក្នុងមណ្ឌលស្តារនីតិសម្បទា ។
- កុមារដែលប្រព្រឹត្តបទល្មើសឧក្រិដ្ឋអាចនឹងត្រូវបញ្ជូនទៅតុលាការព្រហ្មទណ្ឌម្តងទៀត ដើម្បីពិចារណាពីក៏រិតទណ្ឌកម្ម ជាថ្មី បើកុមារនោះមិនមានការកែប្រែក្នុងមណ្ឌល ។

## បង្កើតច្បាប់ពិសេសស្តីពីមណ្ឌលស្តារនីតិសម្បទា

- ត្រូវបង្កើតច្បាប់ពិសេសស្តីពីការបង្កើតមណ្ឌលស្តារនីតិសម្បទា និង ជំរក
- កុមារដែលមានអាយុលើសពី ១៣ ដល់ ១៨ ឆ្នាំ ដែលមានទោសព្រហ្មទណ្ឌ និងកុមារអនាថា ឬគ្មានអាណាព្យាបាលត្រូវបង្ខំដាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទា ។

- មណ្ឌលស្តារនីតិសម្បទាអាចជារបស់រដ្ឋ ឬ ផ្តល់អាជ្ញាប័ណ្ណដោយរដ្ឋ។

**បង្កើតច្បាប់ពិសេសស្តីពីមណ្ឌលស្តារនីតិសម្បទា**

**អំណាចមេបា:**

- ក្រសួងសង្គមកិច្ចមានសិទ្ធិសំរេចអំណាចមេបាចំពោះកុមារអនាថា និងកុមារគ្មានអាណាព្យាបាល។
- ឪពុកម្តាយកុមារអាចធ្វើពាក្យសុំទៅក្រសួងសង្គមកិច្ច ដើម្បីទាមទារកូនមកវិញ។ ក្នុងករណីដែលក្រសួងមិនឱ្យ ឪពុកម្តាយអាចធ្វើពាក្យទៅតុលាការ។

## អនុសាសន៍ចំពោះសម្ព័ន្ធអង្គការកូសេកាំ

- សម្ព័ន្ធអង្គការកូសេកាំគួរតែបង្កើតគោលដៅរបស់អនុគណៈកម្មការនីតិកម្ម សំរាប់តស៊ូមតិច្បាប់ដូចដែលលើកកន្លងមកក្នុងអនុគណៈកម្មការត្រូវបែងចែកគោលដៅទទួលខុសត្រូវ ដូចជាអង្គការ “ក” ដឹកនាំការតស៊ូមតិ ច្បាប់ “ក” ។ល។
- សម្ព័ន្ធអង្គការកូសេកាំ គួរមានវិធានការជួយសមាជិកក្នុងរឿងក្តីជួញដូរកុមារ ។

**សំណួរ. តើកន្លងមកច្បាប់របស់រដ្ឋបានតាក់តែងហើយ ឬនៅស្តីពីការការពារដល់កុមារ?**

យើងនៅមិនទាន់មានច្បាប់ទាំងនេះនៅឡើយទេ តែយើងមានច្បាប់ស្តីពីការប្រឆាំងការរំលោភលើកុមារ ប៉ុន្តែមិនបានអនុវត្តឱ្យបានពេញលេញទេ ព្រោះខ្វះភស្តុតាង ចំណែកឯការធ្វើកោសល្យវិច្ច័យមិនមានលក្ខណៈគ្រប់គ្រាន់។

# ឧបសម្ព័ន្ធទី៣:

## បញ្ជីឈ្មោះអ្នកចូលរួម សិក្ខាសាលាបូកសរុបលទ្ធផលប្រចាំឆ្នាំ ២០០៥

## នៅសណ្ឋាគារឆ្នេរសមុទ្ធ ក្រុងព្រះសីហនុ

## ថ្ងៃទី ៣០-៣១ ខែ ធ្នូ ឆ្នាំ ២០០៥

| ល.រ | ឈ្មោះ | ភេទ | អង្គការ | តួនាទី | ទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | សុក សំអឿន | ប | **CDP** | នាយកប្រតិបត្តិ | ០១២ ៩០១ ១៩៩ |
| ២ | ទូន វិចិត្រ | ប | **COSECAM** | ប្រធានសំរបសំរួលសម្ព័ន្ធ | ០១២ ៣៤៣ ១២២ |
| ៣ | អ៊ិតខៀវ ហ៊ូបេត្តី | ស | **PJJ** | ជំនួយការមេធាវី | ០១២ ៩១៣ ៥៣២ |
| ៤ | អ៊ិន ជំនោរ | ប | **CHO** | នាយកប្រតិបត្តិ | ០១២ ៨៣៣ ៥០០ |
| ៥ | ភោគ ប៊ុនរឿន | ប | **CCASVA** | នាយកប្រតិបត្តិ | ០១២ ៨៨៨ ៦១៣ |
| ៦ | វ៉ែន សារឿន | ប | **HCC** | មន្ត្រីគ្រប់គ្រងមណ្ឌល | ០១២ ៩២៥ ៩៤៦ |
| ៧ | ហ៊ុន ផាណ្ណា | ស | **CWDA** | មន្ត្រីសំរបសំរួល | ០១២ ៩៩៥ ១៩៩ |
| ៨ | សុខ សុគ្គាវី | ស | **KNKS** | នាយកប្រតិបត្តិ | ០១១ ៥៨៣ ៨៦០ |
| ៩ | ឃួន ឈឿត | ប | **PTD** | មន្ត្រីសំរបសំរួល | ០១២ ៧៥៦ ១៩៦ |
| ១០ | ផន ធារិន | ប | **Neavea Thmey** | មន្ត្រីស្រាវជ្រាវ/តស៊ូមតិ | ០១២ ៩១៣ ៥៤៦ |
| ១១ | គង់ សុភា | ប | **KnK** | មន្ត្រីគំរោង | ០១២ ៦៥៨ ១៦២ |
| ១២ | ផន ដារ៉ារិទ្ធ | ប | **CCHDO** | នាយកប្រតិបត្តិ | ០១២ ៣៨៦ ៣៨៧ |
| ១៣ | យី ចាន់តារា | ប | **CCPCR** | មន្ត្រីសំរបសំរួលគំរោង | ០១២ ៨៣០ ២៩៥ |
| ១៤ | ទេព សុវណ្ណថា | ប | **Anakot Koma** | ជំនួយការ | ០១២ ៦៧៤ ២៤៣ |
| ១៥ | គង់ ម៉ារ៉ាឌី | ស | **CAMP** | មន្ត្រីតំណាង | ០១២ ៦៩៩ ៥៨៣ |
| ១៦ | ឡុង សារ៉ាន់ | ស | **KMR** | មន្ត្រីសង្គមកិច្ច | ០១២ ៨៨៦ ៨៥៥ |
| ១៧ | សំ សុវណ្ណារិទ្ធ | ប | **Goutte D'eau** | នាយក | ០១២ ៩៨៥ ៣៨៤ |
| ១៨ | សៀ សុវិទ្យា | ស | **COSECAM** | មន្ត្រីកម្មវិធី ស្តារនីតិសម្បទា និងសមាហរណកម្ម | ០១២ ៤១៥ ៨០៨ |
| ១៩ | ង៉ែត សុភាព | ប | **COSECAM** | ជំនួយការរដ្ឋបាល | ០១២ ៤៤១ ១០៤ |
| ២០ | ឯម ពូល | ប | **COSECAM** | មន្ត្រីកម្មវិធី អភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស | ០១២ ៩១៧ ៣៩៨ |

| | | | | | |
|---|---|---|---|---|---|
| ២១ | កៅ សុខដែត | ស | COSECAM | ជំនួយការកម្មវិធី អភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស | ០១២ ៩៣៣ ១៣៥ |
| ២២ | សូ សុខប៊ុនថេត | ប | COSECAM | ជំនួយការកម្មវិធី តស៊ូមតិ | ០១២ ៩៥៨ ៨៨០ |
| ២៣ | ព្រំ ផលឌីន | ស | COSECAM | ជំនួយការកម្មវិធី ស្តារនីតិសម្បទា និងសមាហរណកម្ម | ០១២ ៤៥៦ ៩៣៥ |
| ២៤ | អន ជាទេវី | ស | COSECAM | ភ្នាក់ងារពិគ្រោះយោបល់ការងារ | ០១១ ៨៥៦ ០០៦ |
| ២៥ | ឆន វុទ្ធី | ប | COSECAM | មន្ត្រីទំនាក់ទំនង | ០១២ ៩៣០ ៦៥៤ |
| ២៦ | អ៊ុំ មុំម៉ារី | ស | COSECAM | ជំនួយការគណនេយ្យ | ០១២ ៩២៧ ៧៧៨ |
| ២៧ | ម៉ៅ វណ្ណះ | ប | COSECAM | អ្នកបើកបរ និងរត់សំបុត្រ | ០១៦ ៧១២ ៤៣៤ |
| ២៨ | សុក សុធន់ | ប | COSECAM | អ្នកហាត់ការ | ០១២ ៤៣៤ ៩៧៥ |
| ២៩ | ថោង ភិរម្យ | ប | COSECAM | មន្ត្រីផ្នែកជំនួយទីផ្សារ និងមុខរបរខ្នាតតូច | ០១២ ៦៧២ ៤៩៨ |

# ឧបសម្ព័ន្ធទី ៤:
# កម្មវិធីសិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ ២០០៥ របស់កូសេកាំ
# នៅក្រុងព្រះសីហនុ
# ៣០-៣១ ខែ ធ្នូ ២០០៥

**ថ្ងៃទី១: ថ្ងៃសៅរ៍ ទី ៣០ ខែធ្នូ ឆ្នាំ ២០០៥**

| ពេលវេលា | អ្នកទទួលខុសត្រូវ | កម្មវិធី |
|---|---|---|
| ៨:០០-៨:២០ | លោក ទូន វិចិត្រ និង លោក សុក សំអឿន | កិច្ចស្វាគមន៍បើកសិក្ខាសាលា និង ការបង្ហាញពីគោលបំណងរបស់សិក្ខាសាលា |
| ៨:២០-៩:៤៤ | | ការបង្ហាញពីលទ្ធផលតាមកម្មវិធីនីមួយៗ |
| | លោក សូ សុខប៊ុនថេត | - កម្មវិធីតស៊ូមតិ និង ស្រាវជ្រាវ |
| | លោក ឯម ពូល | - កម្មវិធី អភិវឌ្ឍន៍ស្ថាប័ន និង ធនធានមនុស្ស |
| | លោក ថោង ភិរម្យ និង លោកស្រី សៀ សុរិទ្យា | - កម្មវិធីស្តារនិតិសម្បទា និង សមាហរណកម្ម |
| | កញ្ញា អ៊ុំ មុំ ម៉ារី និង លោក ង៉ែត សុភាព | - ការងារ រដ្ឋបាល និង ហិរញ្ញវត្ថុ |
| | | សំនួរ ចំលើយ |
| ៨:៤៥-១០:០០ | សំរាក | |
| ១០:០០-១១:០០ | លោក ទូន វិចិត្រ | ការសង្ខេប និង ពិនិត្យឡើងវិញលើរចនាសម្ព័ន្ធ កូសេកាំ គោលនយោបាយ អាណត្តិ និងតួនាទីនៃ: |
| | | - គណៈកម្មាការនាយក |
| | | - អង្គការសមាជិកកូសេកាំ (Delegates) |
| | | - អនុគណៈកម្មាការ |
| | | - សំណួរ ចំលើយ |
| ១១:០០-១២:០០ | អ្នកចូលរួមទាំងអស់ | ពិភាក្សាជាក្រុម |
| ១២:០០-១៤:០០ | សំរាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៥:៣០ | អ្នកចូលរួមទាំងអស់ | ពិភាក្សាជាក្រុមបន្ត |
| ១៥:៣០-១៥:៤៥ | សំរាក | |
| ១៥:៤៥-១៦:៣០ | តំណាងក្រុមនីមួយៗបង្ហាញរបាយការណ៍លទ្ធផលក្រុមពិភាក្សា | |
| ១៦:៣០-១៧:០០ | លោក ទូន វិចិត្រ | សរុបលទ្ធផលថ្ងៃទី១ |
| | | |

| **ថ្ងៃទី២:** | **ថ្ងៃអាទិត្យ ទី ៣១ ខែធ្នូ ឆ្នាំ ២០០៥** | |
|---|---|---|
| **ពេលវេលា** | **អ្នកទទួលខុសត្រូវ** | **កម្មវិធី** |
| ៨:០០-៨:១៥ | លោក ឯម ពូល | សង្ខេបសកម្មភាពថ្ងៃទី១ |
| ៨:១៥-៩:១៥ | លោក សុក សំអឿន | ការបង្ហាញអំពី ច្បាប់ និង កុមារ |
| ៩:១៥-១០:១៥ | ការបង្ហាញពីអំពីផែនការកម្មវិធីសំរាប់ឆ្នាំ២០០៦ | |
| | លោក សូ សុខប៊ុនថេត | - កម្មវិធីតស៊ូមតិ និង ស្រាវជ្រាវ |
| | លោក ឯម ពូល | - កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និង ធនធានមនុស្ស |
| | អ្នកស្រី សៀ សុវិទ្យា | - កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ |
| | លោក ថោង ភិរម្យ | - កម្មវិធីស្តារនិតិសម្បទា និង សមាហរណកម្ម |
| ១០:១៥-១០:៣០ | សំរាក | |
| ១០:៣០-១២:០០ | អ្នកចូលរួមទាំងអស់ | ចែកក្រុមពិភាក្សា |
| ១២:០០-១៤:០០ | សំរាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៥:០០ | អ្នកចូលរួមទាំងអស់ | ពិភាក្សាក្រុមបន្ត |
| ១៥:០០-១៥:៤៥ | តំណាងក្រុមនីមួយៗ | បង្ហាញលទ្ធផលតាមក្រុម |
| ១៥:៤៥-១៦:០០ | សំរាក | |
| ១៦:០០-១៧:០០ | លោក ទូន វិចិត្រ | បូកសរុបលទ្ធផលសិក្ខាសាលា<br>និងប្រកាសបិទកម្មវិធី |

**ថ្ងៃទី៣:** **ថ្ងៃ អាទិត្យ ទី ០១ ខែ មករា ឆ្នាំ ២០០៦**

**ពេលព្រឹក** ការប្រជុំកសាងសមត្ថភាពក្រុមការងារបុគ្គលិក កូសេកាំ

**ពេលល្ងាច** ដំណើរកំសាន្ត

**ថ្ងៃទី៤:** **ថ្ងៃ ច័ន្ទទី ០២ ខែ មករា ឆ្នាំ ២០០៦**

**ពេលព្រឹក** ការធ្វើដំណើរត្រឡប់មកភ្នំពេញវិញ